**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et Des Sciences Économiques**

**Royal University of Law and Economic**

# សារណាបញ្ចប់ការសិក្សា

# ចៅក្រមស៊ើបសួរក្នុងរឿងក្ដីព្រហ្មទណ្ឌនៅសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយនិស្សិតឈ្មោះ

កញ្ញា **ដានី ស្រស់**

លោក **ឡុង រត្តនា**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ដានី ស្រស់** និង **ឡុង រត្តនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២២ ក្នុងឆ្នាំសិក្សា ២០១៨-២០២២ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមធ្វើការថ្លែងអំណរគុណ និងដឹងគុណដ៏ជ្រាលជ្រៅ ដែលមិនអាចធ្វើការកាត់ថ្លៃបានដល់លោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរនាក់ លោកឪពុកឈ្មោះ **ឈាន ដានី** និងម្ដាយឈ្មោះ **ចាំ ពួច** និង លោកឪពុកឈ្មោះ **ឡុង ឡួន** និងម្ដាយឈ្មោះ **កុយ ឌៀប**។ ដែលបានផ្ដល់កំណើតដល់រូបយើងខ្ញុំ លះបង់នូវកម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គ និងបានចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌គឺ មេត្តា ករុណា ដែលប្រកបដោយសុជីវធម៌ ចេះស្រឡាញ់និងជួយអ្នកដទៃ និងចូលរួមសកម្មភាពសង្គមជាតិក្នុងនាមជាចំណែកមួយនៃប្រទេស។ ព្រមទាំងបានផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងការស្នាក់នៅ ការរៀនសូត្រតាំងពីបឋមសិក្សារហូតដល់កម្រិតថ្នាក់បរិញ្ញាបត្រ។ ការប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត លះបង់គ្រប់បែបយ៉ាងដើម្បីឱ្យកូនក្លាយជាអ្នកមានចំណេះដឹង ជំនាញ មួយរូបរស់នៅក្នុងសង្គមជាការលះបង់មួយយ៉ាងធំធេងនេះណាស់។

យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម លុយ ចន្ធា** ដែលជាសាកលវិទ្យាធិការ និង លោក-លោកស្រី សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់នូវការអប់រំ ចំណេះដឹង ព្រមទាំងក្រមសីលធម៌ដល់រូបយើងខ្ញុំក្នុងអំឡុងពេល០៤ឆ្នាំ កន្លងមកនេះ។ ជាពិសេសយើងខ្ញុំទាំងពីនាក់ក៏មិនភ្លេចនូវការសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ លោកគ្រូសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលជាសាស្ត្រចារ្យប្រកបដោយគតិបណ្ឌិត ប្រកបដោយប្រសិទ្ធភាព លើកទឹកចិត្តដល់ខ្ញុំទាំងពីរនាក់រហូត ផ្ដល់កិត្តិយសក្នុងការចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ជ្រោមជ្រែង បង្ហាត់បង្រៀន ជាគំនិតយោបល់ដល់ការសរសេរសារណានេះឡើងបានដោយជោគជ័យ។ ម៉្យាងទៀតយើងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងនៃបណ្ណាល័យនីតិសាស្ត្រ បានរៀបចំនិងគ្រប់គ្រងឯកសារ ព្រមទាំងសៀវភៅយ៉ាងសម្បូរបែបដែលបានបង្កជាលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវមួយនេះឡើងដោយជោគជ័យ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងពួងលើលោកនេះឱ្យជួយតាមថែរក្សាដល់លោកអ្នកមានគុណ ថ្នាក់ដឹកនាំសាលា លោកគ្រូអ្នកគ្រូ សាស្ត្រចារ្យគ្រប់រូប ជាពិសេសលោកគ្រូសាស្ត្រចារ្យដឹកនាំ បងប្អូន ផៅមចម្បង មិត្តរួមជំនាន់ទាំងអស់ ឱ្យជួបតែសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ពេលវេលា នូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅលើសកលលោកយើងនេះមិនសូវមានច្រើនទេ ចំពោះប្រព័ន្ធនៃចៅក្រមលើការស៊ើបសួរនេះឡើយ។ ចំណែកកម្ពុជាយើងវិញ ដើម្បីធានាឱ្យមានភាពយុត្តិធម៌ប្រកបដោយភាពឆាប់រហ័សបានបង្កើតឱ្យមាននូវដំណាក់កាលចៅក្រមស៊ើបសួរនេះឡើង ដើម្បីឱ្យមានភាពច្បាស់លាស់បន្ថែមទៀត ចំពោះដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ សព្វថ្ងៃនេះមានយុវជនកម្ពុជាជាច្រើនបានកំពុងខិតខំសិក្សាលើច្បាប់ខ្មែរ និងច្បាប់បរទេសមួយចំនួនដែលជាការរួមចំណែកក្នុងកសាង និងផ្សព្វផ្សាយនីតិកម្ពុជាឱ្យកាន់តែមានភាពទូលំទូលាយជាងមុនជាមួយនឹងថ្នាក់ដឹកនាំ។ ក្នុងចំណោមនោះរូបខ្ញុំទាំងពីរនាក់ក៏មានគោលបំណងក្នុងការជំរុញឱ្យមានការសិក្សាស្រាវជ្រាវ និងចង់លើកកម្ពស់ការអប់រំផ្នែកនីតិសាស្ត្រនៅកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើង ហើយមានមហាជនកាន់តែយល់ដឹងច្រើនអំពីប្រព័ន្ធតុលាការកម្ពុជា។ យើងដឹងហើយថាវិស័យច្បាប់ព្រហ្មទណ្ឌនៅកម្ពុជាកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយក៏ជាផ្នែកមួយដែលមានសារៈសំខាន់ណាស់នៅក្នុងជីវភាពរស់នៅសព្វថ្ងៃនេះ ដែលពិភពលោកក៏បានយកចិត្តទុកដាក់ខ្លាំងណាស់ដែរចំពោះបញ្ហាសិទ្ធិសេរីភាពរបស់បុគ្គល។ ពីព្រោះថា បើកាលណាមានអំពើល្មើសណាមួយកើតឡើងនៅក្នុងសង្គម វាមិនត្រឹមតែប៉ះពាល់ដល់ជនរងគ្រោះក្រុមគ្រួសារ អនាគតជនល្មើសផ្ទាល់នោះទេ ប៉ុន្តែវាបានជះឥទ្ធិពលដល់សណ្ដាប់ធ្នាប់សាធារណៈ កាលណាបើមិនមានចំណាត់ការបន្ថែមពីលើនេះទៀតនោះទេ វាថែមទាំងធ្វើឱ្យមានការរំខានយ៉ាងខ្លាំងទៅលើផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិផងដែរ។ ដើម្បីជាការចូលរួមចំណែកកាត់បន្ថយការខ្វះខាតនីតិវិធីក្នុងការអនុវត្ត និងការយល់ដឹងបន្ថែមរបស់បងប្អូនប្រជាពលរដ្ឋទៅលើវិស័យច្បាប់ព្រហ្មទណ្ឌនៅកម្ពុជា ទើបយើងខ្ញុំទាំងពីរនាក់បានធ្វើការសម្រេចជ្រើសរើសយកមកធ្វើការស្រាវជ្រាវ។ ទោះបីប្រធានបទនេះពុំមែនជាករណីថ្មីនោះទេ ប៉ុន្តែដោយសារតែយើងខ្ញុំទាំងពីរនាក់យល់ឃើញថាពិតជាសារៈសំខាន់ណាស់ លើនីតិវិធីមួយដែលធ្វើឡើងដោយចៅក្រមស៊ើបសួរនៅតាមសាលាដំបូងដើម្បីស្វែងរកឱ្យឃើញនូវការពិត និងពិរុទ្ធភាព។ ហើយកាលណាបុគ្គលណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌពុំអាចឱ្យអ្នកផ្សេងមកទទួលកំហុសនោះទេ គឺបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នឹងត្រូវទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមច្បាប់ជាធរមាន។ ទោះបីជាកន្លងមកមានការចងក្រងជាសារណាច្រើនក៏ពិតមែន តែបែបបទនីតិវិធី និងការផ្ដល់ជាគំនិតយោបល់ ការពន្យល់មិនដូចគ្នាទាំងអស់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការសរសេរសារណាមួយនេះឡើងដើម្បីបំពេញបន្ថែមនូវចំណុចពីមុនមកក៏ដោយ ការលើកមកស្រាវជ្រាវិញនេះពិតជាមានចំណុចដែលខ្វះខាតណាមួយជាក់ជាមិនខាន។

ដូច្នេះយើងខ្ញុំទាំងពីរនាក់ នៅតែរង់ចាំទទួលនូវការរិះគន់ដើម្បីស្ថាបនាពីសំណាក់សាស្ត្រាចារ្យ និស្សិតនិងមិត្តអ្នកអានគ្រប់ស្រទាប់វណ្ណៈ ដើម្បីធ្វើការកែលម្អសារណាមួយនេះឡើងឱ្យកាន់តែមានភាពល្អប្រសើរ និងអាចទទួលយកបានឱ្យទាន់ការវិវត្តរបស់សង្គមជាតិយើងបច្ចុប្បន្ន។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម**................................................................................................................១

## ជំពូកទី១

## សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរនៅសាលាដំបូង

**ផ្នែកទី១៖ អំពីចៅក្រមស៊ើបសួរ**.......................................................................................៦

កថាខណ្ឌទី១៖ និយមន័យ...............................................................................................៦

កថាខណ្ឌទី២៖ លក្ខណៈសម្បត្តិដើម្បីក្លាយជាចៅក្រម.......................................................៧

ក. តាមការប្រឡងប្រជែង.........................................................................................៧

ខ. ការបណ្តុះបណ្តាលសិស្សចៅក្រម...........................................................................៧

គ. ការតែងតាំង........................................................................................................៨

កថាខណ្ឌទី៣៖ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ.................................................................៨

ក. សមត្ថកិច្ចតាមសាច់រឿង........................................................................................៨

ខ.សមត្ថកិច្ចតាមដែនដី.............................................................................................៩

កថាខណ្ឌទី៤៖ គោលការណ៍នៃការស៊ើបសួរ.................................................................... ៩

កថាខណ្ឌទី៥៖ វិសមិតភាពការស៊ើបសួរ........................................................................១១

**ផ្នែកទី២៖ នីតិវិធីនៃការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ**.........................................១២

កថាខណ្ឌទី១៖ ការទទួលពាក្យបណ្តឹង.............................................................................១២

ក. សេចក្តីសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរដោយព្រះរាជអាជ្ញា..........................................១២

ខ.ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី.......................................................................១២

កថាខណ្ឌទី២៖ អានុភាពនៃបណ្តឹងទទួលបានតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា...................១៣

ក. ភាពមិនអាចធ្វើការដកបណ្តឹងបាន.......................................................................១៤

ខ. កាតព្វកិច្ចចំពោះការស៊ើបសួរ...............................................................................១៤

កថាខណ្ឌទី៣៖ វិសាលភាពនៃការស៊ើបសួរ.....................................................................១៤

# ជំពូកទី២
# ការស្រាវជ្រាវ និងវិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ


**ផ្នែកទី១៖ អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**............១៦
កថាខណ្ឌទី១៖ វិធីសាស្ត្រនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ............១៦
ក. ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ............១៦
ខ .ការសួរចម្លើយជនត្រូវចោទ............១៧
គ. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី............១៩
ឃ. ការស្តាប់ចម្លើយសាក្សី............១៩
ង. ការចុះទៅដល់ទីកន្លែងកើតហេតុ............២១
ច. ការឆែកឆេរ និងការចាប់យកវត្ថុតាង............២១
ឆ. កោសលវិច័យ............២២
ជ. ការស្តាប់ទូរស័ព្ទ និងថតការសន្ទនា............២៥
កថាខណ្ឌទី២៖ ដីកាចាត់ឱ្យស៊ើបសួរជំនួស............២៦
កថាខណ្ឌទី៣៖ ការស្នើសុំបំពេញកិច្ច............២៦
ក. ការបំពេញកិច្ចដោយព្រះរាជអាជ្ញា............២៧
ខ. ការបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី............២៧
គ. ការបំពេញកិច្ចដោយជនត្រូវចោទ............២៧
**ផ្នែកទី២៖ វិធានការនិរន្តរាយ**............២៨
កថាខណ្ឌទី១៖ ការចេញដីកា............២៨
ក. ដីកាបង្គាប់ឱ្យចូលខ្លួន............២៨
ខ. ដីកាបង្គាប់ឱ្យនាំខ្លួន............២៩
គ. ដីកាបង្គាប់ឱ្យចាប់ខ្លួន............៣០
ឃ. ដីកាបង្គាប់ឱ្យឃុំខ្លួន............៣១
កថាខណ្ឌទី២៖ ការឃុំខ្លួនបណ្តោះអាសន្ន............៣១
ក. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន............៣១
ខ. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន............៣២
កថាខណ្ឌទី៣៖ ដីកាដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ............៣៣

ក. តាមរយៈចៅក្រមស៊ើបសួរ.....................................................................................................៣៣
ខ. តាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា....................................................................................................៣៣
គ. តាមបណ្ដឹងសុំរបស់ជនត្រូវចោទ....................................................................................................៣៤
កថាខណ្ឌទី៤៖ ការត្រួតពិនិត្យតាមផ្លូវតុលាការ..........................................................................................៣៤
ក. លក្ខខណ្ឌនៃការត្រួតពិនិត្យ...........................................................................................................៣៤
ខ. មូលហេតុនៃការដាក់ឱ្យត្រួតពិនិត្យ.....................................................................................................៣៥
កថាខណ្ឌទី៥៖ បុគ្គលដែលអាចកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ.............................................................៣៥
ក. ចៅក្រមស៊ើបសួរ.............................................................................................................................៣៥
ខ. បណ្ដឹងសុំរបស់ព្រះរាជអាជ្ញា........................................................................................................... ៣៥
គ. បណ្ដឹងសុំរបស់ជនត្រូវចោទ...........................................................................................................៣៦
កថាខណ្ឌទី៦៖ ស្ថានភាពគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យរបស់តុលាការ...........................................................៣៦

## ជំពូកទី៣

## ការបិទបញ្ចប់ការស៊ើបសួរ

**ផ្នែកទី១៖ នីតិវិធីត្រៀមបិទការស៊ើបសួរ**..........................................................................៣៧

កថាខណ្ឌទី១៖ ការជូនដំណឹងពីការបិទការស៊ើបសួរ..............................................................................៣៧

ក. ការបិទការស៊ើបសួរតាមបណ្ដឹងសុំរបស់គូភាគី..............................................................................៣៨

ខ. តាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាចំពោះគំហើញរបស់ចៅក្រមស៊ើបសួរ....................៣៨

**ផ្នែកទី២៖ ការបិទការស៊ើបសួរដោយចៅក្រមស៊ើបសួរ**..................................................................៤០

កថាខណ្ឌទី១៖ ប្រភេទដីកាដំណោះស្រាយ..............................................................................................៤០

ក. ដីកាបញ្ជូនទៅជំនុំជម្រះ......... ..........................................................................................................៤១

ខ .ដីកាលើកលែងការចោទប្រកាន់.............................................................................................................៤២

កថាខណ្ឌទី៣៖ បើកការស៊ើបសួរលើបន្ទុកថ្មី..............................................................................................៤៣

**សេចក្ដីសន្និដ្ឋាន**.................................................................................................................................៤៥

**អនុសាសន៍**..........................................................................................................................................៤៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាជាប្រទេសមួយដែលធ្លាប់តែមានអារ្យធម៌ឧត្តុង្គឧត្តម និងមានភាពស្តុកស្តម្ភធំទូលាយ ចុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ ប៉ុន្តែទិដ្ឋភាពដែលមានភាពសម្បូរសប្បាយរុងរឿងនេះមិនបានស្ថិតនៅយូរអង្វែងនោះទេ ក៏បានធ្លាក់ខ្លួនដ៏សែនរន្ធត់ក្នុងអំឡុងពេលពីរទសវត្សរ៍ចុងក្រោយនេះឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ ទ្រុឌទ្រោម ឱនភាពមហាសោកស្តាយរហូតដល់ចំណុចសូន្យ ពោលគឺស្ថិតនៅរបបប្រល័យពូជសាសន៍ផ្តាច់ការ នៃកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមដែលធ្វើឱ្យព្រះរាជាណាចក្រកម្ពុជារងទុក្ខវេទនា ធ្វើទុក្ខបុកម្នេញជីវិតរបស់ប្រជាពលរដ្ឋខ្មែរអស់រយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។

បន្ទាប់ពីបានរួចផុតពីរបបដ៏ឃោរឃៅមួយនេះមក ប្រទេសកម្ពុជាបានក្រោកឈរឡើងក្នុងការចងបាច់គ្នាក្នុងឆន្ទៈមោះមុតប្តូរផ្តាច់រួបរួមគ្នាពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យ ថ្លៃថ្នូ និងអារ្យធម៌អង្គរដ៏បវរនៃយើង ហើយបានកសាងប្រទេសជាតិមួយទៅជាកោះសន្តិភាពឡើងវិញ។ ដែលស្ថិតនៅក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ស្របតាមគោលការណ៍របបលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស តាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានប្រកាសឱ្យប្រើប្រាស់ទូទាំងប្រទេសនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ លើសពីនេះទៅទៀតរដ្ឋធម្មនុញ្ញកម្ពុជាក៏បានទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ព្រមទាំងអនុសញ្ញាទាំងឡាយណាទាក់ទងទៅនិងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ ដែលបណ្តាលឱ្យកម្ពុជារបស់យើងមានភាពរីកចម្រើនឡើងវិញនូវវិស័យអប់រំ វិស័យសុខាភិបាល វិស័យទំនាក់ទំនងការទូត ព្រមទាំងវិស័យផ្សេងៗទៀតកំពុងតែមានការអភិវឌ្ឍ ជាពិសេសលើវិស័យយុត្តិធម៌ដែលនឹងផ្តល់ជូនឱ្យជនរងគ្រោះ ជនត្រូវចោទនៅក្នុងរឿងព្រហ្មទណ្ឌនេះតែម្តង។ ការផ្តល់នូវភាពយុត្តិធម៌នេះដោយមានការឆ្លងកាត់នូវនីតិវិធីជាច្រើន តាមដំណាក់កាលសំខាន់ៗដូចមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌថ្មីនេះ ដោយមានដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះផងដែរ។ ដោយឡែកចំពោះសារណារបស់ខ្ញុំទាំងពីរនាក់នេះវិញលើកឡើងមកធ្វើការស្រាវជ្រាវតែដំណាក់ស៊ើបសួររបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលការស៊ើបសួរនេះបានដើរតួនាទីយ៉ាងសំខាន់ណាស់នៅដំណើរការនីតិវិធីស៊ើបសួរ ទៅលើប្រភេទនៃបទល្មើសដែលត្រូវបានចោទប្រកាន់ដោយតំណាងអយ្យការមកលើជនត្រូវចោទតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយចៅក្រមស៊ើបសួរ

នេះក៏មានអំណាចគ្រប់គ្រាន់ក្នុងការស្វែងរកនូវភស្តុតាងទាំងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក និងវិធានការផ្សេងៗទៀតដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ។

ដូច្នេះហើយដំណាក់កាលនៃចៅក្រមស៊ើបសួរគាត់មានអំណាចជាច្រើនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនជាក់ស្តែងការត្រូវយកជនត្រូវចោទមកធ្វើការឃុំខ្លួនបណ្តោះអាសន្ន ទោះបីជាករណីនេះមានលក្ខណៈធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គលក៏ពិតមែន តែដើម្បីការពារសុវត្ថិភាពរបស់ជនរងគ្រោះ ជនត្រូវចោទផ្ទាល់ក៏សំខាន់ ព្រោះថាអាចមានករណីខ្លះជនត្រូវចោទគាត់ពុំមានចេតនាចង់ប្រព្រឹត្តបទល្មើសនោះទេ ប៉ុន្តែដោយមានការបង្ខិតបង្ខំពីតតិយជនណាម្នាក់ ប្រសិនបើចៅក្រមស៊ើបសួរមិនធ្វើការឃុំខ្លួនបណ្តោះអាសន្ននោះទេ អាចបណ្តាលឱ្យជនត្រូវចោទមានគ្រោះថ្នាក់ដល់ជីវិតថែមទៀតបាន។ ហេតុនេះហើយចៅក្រមស៊ើបសួរ ជាផ្នែកមួយក្នុងការចូលរួមចំណែក ស្វែងរកឱ្យឃើញនូវភស្តុតាងការពិតទាំងឡាយណាដែលមានផលប្រយោជន៍ដល់រឿងក្តីនេះ ដើម្បីយកមកបកស្រាយឱ្យឃើញពីភាពត្រឹមត្រូវនៃរឿងក្តីនីមួយៗ និងផ្តល់ភាពជឿទុកចិត្តដល់គូភាគីក្នុងការទទួលបាននូវភាពយុត្តិធម៌មួយយ៉ាងពិតប្រាកដ។

## ២. ចំណោទបញ្ហា និងការដោះស្រាយនៃការស្រាវជ្រាវ

នៅក្នុងសៀវភៅសារណាមួយច្បាប់នេះ ដែលបានធ្វើការផ្តល់នូវចំណងជើងថា"ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង"ក្រុមខ្ញុំទាំងពីរនាក់បានធ្វើការកំណត់នូវចំណោទបញ្ហាចំនួន៣យ៉ាងជាក់លាក់រួមមាន៖

១.តើនីតិវិធីនៃការបើកការស៊ើបសួរត្រូវប្រព្រឹត្តទៅបានដោយមានលក្ខខណ្ឌអ្វីខ្លះ?

២.តើការស្រាវជ្រាវ និងវិធាននិរន្តរាយរបស់ចៅក្រមស៊ើបសួរមាននីតិវិធីអ្វីខ្លះ?

៣. ដំណាក់កាលបិទការស៊ើបសួរត្រូវតម្រូវឱ្យចៅក្រមស៊ើបសួរគោរពតាមវិធានការអ្វីខ្លះ?

ចំពោះចម្លើយដែលនឹងត្រូវធ្វើការឆ្លើយតបទៅលើបញ្ហាទាំងអស់នេះនឹងធ្វើការបង្ហាញទាំងស្រុងនៅជំពូកទី១ដែលនឹងឆ្លើយតបចំពោះសំណួរទី១ សំណួរទី២ និងមានការបង្ហាញជូននៅក្នុងជំពូកទី២ ចំណែកឯចំណោទបញ្ហាទី៣វិញ និងមានការស្រាយចម្ងល់ជូននៅជំពូកទី៣ ដែលមានការសម្រាយជូននៅទំព័របន្តបន្ទាប់ទៀតនេះ។

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវ និងការចងក្រងជាសៀវភៅទៅលើប្រធានបទ ស្តីពីចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងនេះគឺមានគោលបំណងយ៉ាងមោះមុតថា អាចនឹងមានការឈ្វេងយល់ឱ្យកាន់តែមានភាពច្បាស់លាស់ និងស៊ីជម្រៅទៅលើនីតិវិធីរបស់ចៅក្រមស៊ើបសួរ ព្រមទាំងអាចក្លាយទៅជាសារៈប្រយោជន៍សម្រាប់ការត្រៀមប្រឡងចូលវិជ្ជាជីវៈជាចៅក្រម មេធាវី ក្រឡាបញ្ជី សាការី អាជ្ញាសាលា ឬការប្រឡងវិជ្ជាជីវៈច្បាប់ផ្សេងៗទៀតនាពេលខាងមុខដែលសម្រាប់ធ្វើជាប្រយោជន៍ឯកសារជំនួយដល់ជនគ្រប់រូបដែលមាន

គោលបំណងចង់ធ្វើការសិក្សាឈ្វេងយល់បន្ថែម ដើម្បីបង្កើនជាចំណេះដឹង ឬយកទៅអនុវត្តនៅក្នុងផ្នែកនីតិវិធីលើវិស័យតុលាការជាដើម។ ជាពិសេសជាងនេះទៅទៀត ក្រុមខ្ញុំទាំងពីរនាក់ក៏នៅមានការរំពឹងថា ឯកសារដែលបានចងក្រងនេះក៏នឹងអាចក្លាយទៅជាមូលដ្ឋានគ្រឹះដែរ សម្រាប់លោកគ្រូអ្នកគ្រូ សាស្ត្រចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានដែលស្រឡាញ់ និងចង់សិក្សាលើវិស័យច្បាប់នៅកម្ពុជា ក៏ដូចជាអាចចូលរួមលើការជំរុញ និងលើកទឹកចិត្តឱ្យប្រជាជនកម្ពុជាឱ្យមានការចូលចិត្តការអានសៀវភៅ ការសិក្សាស្រាវជ្រាវ ធ្វើការវិភាគទៅលើទិដ្ឋភាពសង្គមជាតិដោយមានការផ្អែកតាមបទដ្ឋានច្បាប់ជាធរមានផងដែរ។ ដែលយើងទាំងពីរនាក់គិតថាការធ្វើបែបនេះក៏ជាការចូលរួមចំណែកមួយជួយអភិវឌ្ឍន៍សង្គមជាតិឱ្យកាន់តែមានភាពរីកចម្រើន ប្រកបដោយចីរភាព និងប្រសិទ្ធភាពបន្តទៀតបាន។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងចំណោទនៃបញ្ហាខាងលើនេះឱ្យមានភាពប្រាកដប្រជាជាងនេះទៅទៀត ក្រុមយើងខ្ញុំបានធ្វើការកំណត់ឯកសារមួយចំនួន ដែលសំខាន់ជាមួយប្រធានបទដើម្បីធ្វើការសិក្សាស្រាវជ្រាវនេះមានទំហំចំពោះតែផ្នែកចៅក្រមស៊ើបសួរនៅសាលាដំបូងរាជធានីខេត្តតែប៉ុណ្ណោះ ដែលចៅក្រមស៊ើបសួរនេះត្រូវបានធ្វើការចាត់តាំងដោយប្រធានតុលាការនីមួយៗនៅតាមសាលាដំបូង។ ចំណែកឯដែនកំណត់នៃការស្រាវជ្រាវលើប្រធានបទនេះវិញ គឺក្រុមខ្ញុំទាំងពីរនាក់នឹងធ្វើការរៀបរាប់តែ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរអំពីដំណើរការបើកការស៊ើបសួរ វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ វិធាននិរន្តរាយ និងនីតិវិធីការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរមកធ្វើការបង្ហាញនៅក្នុងសារណាមួយនេះតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ជាការពិតណាស់ការស្រាវជ្រាវនេះពិតជាមានផលលំបាកណាស់ដែរ ព្រោះយើងត្រូវចំណាយពេលវេលាច្រើនក្នុងការស្រាវជ្រាវឯកសារឱ្យបានទូលំទូលាយ ទោះបីជាខ្ញុំទាំងពីរនាក់មានការងាររវល់ជាច្រើនត្រូវបំពេញក្នុងអំឡុងពេលសរសេរសារណានេះឡើងក៏ដោយ ប៉ុន្តែនៅតែចំណាយទាំងកម្លាំងកាយចិត្ត ដែលការស្រាវជ្រាវមួយនេះទាមទារឱ្យយើងត្រូវមានចំណង់ចំណូលចិត្ត ទៅលើការស្រាវជ្រាវព័ត៌មានដែលពាក់ព័ន្ធនោះទើបបានជោគជ័យទៅបាន។ តែទោះបីជាមានផលវិបាកយ៉ាងណាក៏ដោយ ក៏យើងទាំងពីរនាក់នៅតែព្យាយាមជម្នះនូវការលំបាកនេះឱ្យខានតែបាន ដោយសារថាក្រុមយើងខ្ញុំបានតាំងចិត្តធ្វើវាតាំងពីដើមទីហើយដើម្បីសម្រេចឱ្យបានគោលបំណងដូចបានរៀបរាប់នៅខាងលើនេះ ព្រោះសារណាមានសារៈសំខាន់ជាច្រើនសម្រាប់យើងខ្ញុំទាំងពីរនាក់ផ្ទាល់ និងសម្រាប់អ្នកសិក្សាវិស័យច្បាប់ផ្សេងទៀតដែលអាចយកទៅប្រើប្រាស់នៅពេលបំពេញការងារដែលមានគុណប្រយោជន៍ និងគុណតម្លៃជាច្រើនទាំងចំណេះដឹងទាក់ទងនិងប្រធានបទនេះរួមមាន៖

- ទទួលបានចំណេះដឹងអំពីរបៀបនៃការចងក្រងជាសៀវភៅ ការរៀបចំប្លង់នៃសារណា
- យល់ដឹងអំពីការប្រើប្រាស់ផ្នែកកុំព្យូទ័រ ដែលកន្លងមកមិនធ្លាប់បានប្រើមុខងារមួយចំនួនឡើយ
- កាន់តែមានការប្រុងប្រយ័ត្នបន្ថែមច្រើនជាងមុនទាក់ទងនិងការប្រើប្រាស់ប្រយោគ ឃ្លោងឃ្លា អក្ខរាវិរុទ្ធ
- យល់ដឹងកាន់តែច្បាស់ពាក់ព័ន្ធតួនាទីរបស់ចៅក្រមស៊ើបសួរលើប្រធានបទសារណានេះទាំងមូល
- ទទួលបានបទពិសោធន៍ថ្មីពីការផ្តល់ចំណេះដឹងដ៏ល្អៗរបស់សាស្ត្រចារ្យណែនាំ និងរៀមច្បងមុនៗ
- បានបន្សល់ទុកនូវស្នាដៃសម្រាប់ទុកជាការស្រាវជ្រាវនៅពេលក្រោយ សម្រាប់ឱ្យអ្នកសិក្សាច្បាប់យកទៅប្រើប្រាស់ស្របតាមកម្មវិធីសិក្សារួមទាំងសិស្សនិស្សិត ជំនាន់ក្រោយយកទៅយកសិក្សាស្រាវជ្រាវបន្តទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវប្រធានបទ

មុនដំបូងតម្រូវឱ្យមានការជ្រើសរើសប្រធានបទ ជ្រើសរើសសាស្ត្រចារ្យណែនាំ ជួបជាមួយសាស្ត្រចារ្យដើម្បីឱ្យគាត់ពិនិត្យលើប្រធានបទ និងយល់ស្របព្រមចុះហត្ថលេខាលើប្រធានបទជាមុនសិនទើបអាចចាប់ផ្តើមរៀបចំប្លង់ ហើយបានធ្វើការដាក់ទម្រង់ជ្រើសរើសសាស្ត្រចារ្យនេះ ទៅអ្នកគ្រប់គ្រងសារណាសម្រាប់ឆ្នាំសិក្សា២០២១-២០២២ ដើម្បីឱ្យគាត់ធ្វើការពិនិត្យ មានការពិភាក្សាក្រុមបន្ថែមទៀត។ រាល់ខ្លឹមសារ ឯកសារពាក់ព័ន្ធ និងព័ត៌មានទាំងឡាយដែលយកមកធ្វើការចងក្រងនៅក្នុងសៀវភៅសារណាមួយនេះ ត្រូវបានឆ្លងកាត់នូវការប្រមូលទិន្នន័យជាច្រើនមកធ្វើជាវិធីសាស្ត្រស្រាវជ្រាវ ដើម្បីបានជោគជ័យជាសៀវភៅមួយក្បាលដែលមានគុណតម្លៃសម្រាប់ក្រុមខ្ញុំទាំងពីរ។

### ក. ការប្រមូលទិន្នន័យ

វិធីសាស្ត្រទាក់ទងនិងការប្រមូលបាននូវទិន្នន័យចម្បង និងបន្ទាប់បន្សំដូចការរៀបរាប់ខាងក្រោមនេះ៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមព្រះរាជអាជ្ញា ច្បាប់ស្តីពីយុត្តិធម៌អនីតិជន។
- ស្រាវជ្រាវតាមរយៈសៀវភៅច្បាប់ដែលមាននៅតាមបណ្ណាល័យ និងតាមប្រព័ន្ធអ៊ីនធើណែត
- និងមានឯកសារសំខាន់ៗផ្សេងទៀតដូចជា សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌដែលបានរៀបរៀងដោយ សាស្រាចារ្យច្បាប់ អ្នកវិជ្ជាជីវៈច្បាប់ គំរូដីកា អត្ថបទច្បាប់ផ្សេងៗ និងឯកសារដែលទទួលបានការណែនាំពីសាស្រាចារ្យដឹកនាំសារណា របាយការណ៍របស់រៀមច្បងមុនៗ ការសួរនាំដោយផ្ទាល់ចំពោះអ្នកដែលធ្លាប់មានបទពិសោធន៍លើប្រធានបទនេះ តាមរយៈកម្មវិធីវិទ្យុ កម្មវីធីបកស្រាយច្បាប់តាមកញ្ចក់ទូរទស្សន៍ សិក្ខាសាលា សារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយនានាផ្សេងទៀត។

**ខ. វិធីសាស្ត្រចងក្រង បញ្ចូលទិន្នន័យ និងព័ត៌មាន**

បន្ទាប់ពីបានប្រមូលទុកនូវឯកសារទាំងអស់នេះហើយ ក្រុមខ្ញុំទាំងពីរនាក់បានធ្វើការបែងចែកចំណុចគ្នាក្នុងរៀបចំវាយអត្ថបទនៅក្នុងកុំព្យូទ័រកម្មវិធី Microsoft Word ទៅតាមជំពូក និងផ្នែកនីមួយៗដូចតាមការរៀបរាប់នៅមាតិកាតាមប្រភេទ និងដោយមានការព្រៀងទុកជាមុនផងដែរចៀសវាងមានការភ័ន្តច្រឡំជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីរកជាដំណោះស្រាយដែលមានលក្ខណៈងាយស្រួលលើការសិក្សាស្រាវជ្រាវនេះ ក៏ដូចជាការឆ្លើយតបទៅលើបញ្ហាគតិយុត្តដែលបានលើកឡើងនៅខាងលើនេះ សារណានៃការស្រាវជ្រាវរបស់ខ្ញុំទាំងពីរនាក់នេះបានធ្វើការលម្អិតដោយមានការបែងចែកជា ០៣(បី) ជំពូកដែលក្នុងនោះរួមមាន៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរនៅសាលាដំបូង**

**ជំពូកទី២៖ ការស្រាវជ្រាវ និងវិធាននិវន្តរាយរបស់ចៅក្រមស៊ើបសួរ**

**ជំពូកទី៣៖ ការបិទបញ្ចប់ការស៊ើបសួរ**

# ជំពូកទី១
# សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ
# នៅសាលាដំបូង

# ជំពូកទី១
# សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរនៅសាលាដំបូង

## ផ្នែកទី១៖ អំពីចៅក្រមស៊ើបសួរ

ចៅក្រមសំដៅដល់មន្ត្រីតុលាការមន្ត្រីអ្នកជម្រះក្តី នេះបើយោងតាមការឱ្យនិយមន័យក្នុងវចនានុក្រមរបស់សម្តេចសង្ឃរាជជួនណាត។ ម្យ៉ាងវិញទៀត ចៅក្រមគឺសំដៅដល់ចៅក្រមអាសនៈ រួមមានជាអាទិ៍ ចៅក្រមជម្រះក្តី និងចៅក្រមស៊ើបសួរ[1]។ ចៅក្រម គឺជាមន្ត្រីសាធារណៈដែលទទួលការជ្រើសតាំងឱ្យដឹកនាំគ្រប់គ្រងកិច្ចការច្បាប់នៅតាមសាលាជម្រះក្តី។ មានតែចៅក្រមទេ ដែលមានសិទ្ធិក្នុងការជម្រះក្តី ដែលចៅក្រម ត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន[2]។ ហើយនៅក្នុងអាជីពរបស់ខ្លួនក្នុងនាមជាចៅក្រមអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាក៏អាចត្រូវបានតែងតាំងជាចៅក្រមវិញបានដែរ[3]។ ជារៀងរាល់ឆ្នាំ ប្រធានសាលាដំបូងចាត់តាំងចៅក្រមស៊ើបសួរម្នាក់ ឬច្រើននាក់ឱ្យស៊ើបសួរទៅតាមការចាំបាច់។ កាលណាមានចៅក្រមស៊ើបសួរច្រើននាក់ក្នុងតុលាការតែមួយ សំណុំរឿងទាំងឡាយត្រូវបានបែងចែកដោយប្រធានតុលាការ។ ចៅក្រមរូបណាដែលទទួលបន្ទុកស៊ើបសួររឿងក្តីណាមួយហើយ មិនអាចធ្វើជាចៅក្រមជំនុំជម្រះរឿងក្តីដដែលនោះបានទេ។ លើសពីនេះទៅទៀតប្រធានតុលាការអាចដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរណាម្នាក់ទៅឱ្យចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀតបាន ដើម្បីជាប្រយោជន៍សម្រាប់ក្នុងការរកយុត្តិធម៌តាមការយល់ឃើញរបស់គាត់ ឬអាចដកតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ឬអាចដកតាមរយៈពាក្យបណ្តឹងរបស់ភាគី(បណ្តឹងដិតជិតចៅក្រម)។

### កថាខណ្ឌទី១៖ និយមន័យ

នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជាការស៊ើបសួរ គឺជាដំណាក់កាលមួយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកនូវការពិតជូនជនរងគ្រោះ និងជនត្រូវចោទជាដើម។

ដំណាក់កាលស៊ើបសួរនេះគឺជាដំណាក់កាលមួយដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ហើយនៅសាលាដំបូងមានមន្ទីរស៊ើបសួរមួយ ដែលអាចមានចៅក្រមមួយរូប ឬច្រើនរូបតាមការចាំបាច់។ ចំណែកនៅសាលាឧទ្ធរណ៍ មានសភាស៊ើបសួរមួយដែលមានចៅក្រមស៊ើបសួរច្រើនរូប។ ហើយមន្ទីរស៊ើបសួរគឺជាយុត្តាធិការស៊ើបសួរនៃតុលាការជាន់ទាបដែលមានអំណាចស៊ើបសួររឿងក្តីទាំងឡាយ ដែលបានប្តឹងចោទដោយមានបើកការស៊ើបសួរដោយព្រះរាជអាជ្ញា ឬជនរងគ្រោះ (ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី)។

[1] មាត្រា ៣ ច្បាប់ស្តីពី លក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា/ឆ្នាំ២០១៤។

[2] មាត្រា ១២៩,រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា ៦ ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ។

[3] មាត្រា ៥,ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា/ឆ្នាំ២០១៤។

យុត្តាធិការស៊ើបសួរ គឺជាតំណាងមួយនៃវិធានស្រាវជ្រាវរបស់ចៅក្រមដែលមានតួនាទីស្វែងរកនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុកដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចឱ្យចៅក្រមស៊ើបសួរ[4]។

**កថាខណ្ឌទី២៖ លក្ខណៈសម្បត្តិដើម្បីក្លាយជាចៅក្រម**

**ក. តាមការប្រឡងប្រជែង**

បុគ្គលដែលត្រូវបានជ្រើសរើសសម្រាប់ឱ្យបំពេញមុខងារជាចៅក្រម និងព្រះរាជអាជ្ញាត្រូវតែជាអ្នកដែលមានសមត្ថភាព និងជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ[5]។ មុននិងក្លាយទៅជាចៅក្រមត្រូវបានអនុញ្ញាតឱ្យមានការប្រឡងជ្រើសរើសជាសិស្សចៅក្រមតម្រូវឱ្យបេក្ខជនទាំងអស់ ដែលចូលរួមប្រកួតប្រជែងនេះបំពេញលក្ខខណ្ឌដូចជា ត្រូវមានសញ្ជាតិខ្មែរពីកំណើត មានអាយុ៣៥(សាមសិបប្រាំ)ឆ្នាំយ៉ាងច្រើនចំពោះបេក្ខជនជានិស្សិត និងមានអាយុ៤០(សែសិប)ឆ្នាំយ៉ាងច្រើនចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រនីតិសាស្ត្រឡើងទៅ មិនដែលមានទោសព្រហ្មទណ្ឌពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។[6]

ចំពោះការជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌចៅក្រម អាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជីដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រនីតិសាស្ត្រឡើងទៅ និងមានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិច៥(ប្រាំ)ឆ្នាំ ហើយមានអាយុមិនឱ្យលើសពី៤៥(សែសិបប្រាំ)ឆ្នាំ គិតដល់ថ្ងៃប្រឡង។ ចំណែកមេធាវីវិញ ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រនីតិសាស្ត្រឡើងទៅ និងបានបំពេញវិជ្ជាជីវៈរបស់ខ្លួនយ៉ាងតិច៥(ប្រាំ)ឆ្នាំអាចចុះឈ្មោះប្រឡងបាន ហើយមានអាយុមិនឱ្យលើសពី៤៥(សែសិបប្រាំ)ឆ្នាំគិតដល់ថ្ងៃប្រឡង។[7]

**ខ. ការបណ្តុះបណ្តាលសិស្សចៅក្រម**

បុគ្គលដែលបានប្រឡងជាប់ជាសិស្សចៅក្រម ត្រូវទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈដែលប្រព្រឹត្តទៅតាមការកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ដោយយោងតាមមាត្រា២៣ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។ ដែលការបណ្តុះបណ្តាលនេះជាទូទៅមានរយៈពេល២ឆ្នាំនៅសាលាភូមិន្ទចៅក្រម ព្រមទាំងឆ្លងកាត់កម្មសិក្សាដែលត្រូវបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

---

[4] មាត្រា ១២៧,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[5] មាត្រា ៤,ច្បាប់ ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា/ឆ្នាំ២០១៤។

[6] មាត្រា ១៩,ច្បាប់ ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា/ឆ្នាំ២០១៤។

[7] មាត្រា ២៣, កថាខណ្ឌទី១, ច្បាប់ ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នសរកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា/ឆ្នាំ២០១៤។

**គ. ការតែងតាំង**

សិស្សចៅក្រមដែលបានជ្រើសរើសតាមបញ្ញត្តិនៃ មាត្រា១៩ និង មាត្រា២៣ ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយភាពជោគជ័យ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ជាចៅក្រមកម្មសិក្សាក្នុងឋានន្តរស័ក្តិជាអនុចៅក្រមថ្នាក់ដំបូង[8]។

**កថាខណ្ឌទី៣៖ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ**

**ក. សមត្ថកិច្ចតាមសាច់រឿង**

តាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌពុំបានទទួលស្គាល់ថា តុលាការទាំងឡាយអាចប្តឹងមកខ្លួនឯងដោយខ្លួនឯងផ្ទាល់ដើម្បីបើកការស៊ើបសួរ ឬវិនិច្ឆ័យលើបទល្មើសព្រហ្មទណ្ឌណាមួយបានឡើយ បើទោះបីតុលាការនោះបានដឹងដោយផ្ទាល់នូវបទល្មើសក៏ដោយ។ ដោយហេតុនេះហើយទើបចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបានលុះត្រាតែបានដឹងរឿងរ៉ាវមួយតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ឬដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខតែប៉ុណ្ណោះ។

ចៅក្រមមានសមត្ថកិច្ចចំពោះប្រភេទបទល្មើសព្រហ្មទណ្ឌទាំងបី (បទលហុ បទមជ្ឈិម បទឧក្រិដ្ឋ) ដែលជាគោលការណ៍រាល់បទល្មើសឧក្រិដ្ឋទាំងអស់ ការស៊ើបសួរត្រូវតែធ្វើឡើងជានិច្ច ដោយឡែកចំពោះបទល្មើសមជ្ឈិមវិញ ការស៊ើបសួរធ្វើក៏បាន ឬមិនធ្វើក៏បានដែរ(មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ផ្អែកតាមមាត្រានេះ យើងអាចធ្វើការបង្ហាញបានត្រង់មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌបានចែងថាៈ បទលួចគឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០(មួយលាន)រៀល ទៅ ៦.០០០.០០០០(ប្រាំមួយលាន)រៀល។

ផ្អែកតាមករណីការលើកឡើងខាងលើនេះយើងអាចភ្ជាប់ជាមួយករណីដែលចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរក៏បាន ឬក៏មិនធ្វើក៏បាន ដែលចំណុចនេះព្រះរាជអាជ្ញាមានជម្រើសពីរក្នុងការចោទប្រកាន់ ជម្រើសទី១ គឺធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ប្រសិនបើតំណាងអយ្យការយល់ឃើញថាបទល្មើសមិនជាក់ស្តែង ឬមិនមានភស្តុតាងបញ្ជាក់គ្រប់គ្រាន់ដែលមិនអាចធ្វើការកំណត់បាននូវអត្តសញ្ញាណរបស់ចារី សហចារីនៃបទល្មើសបាន។ ចំណែកជម្រើសទី២ បើសិនបទល្មើសខាងលើនេះមានភស្តុតាងបញ្ជាក់ច្បាស់លាស់ មានសាក្សី និងជនល្មើសត្រូវបានកំណត់អត្តសញ្ញាណសមល្មមអាចយកទៅជំនុំជម្រះបាន នោះ

[8] មាត្រា ២៤,កថាខណ្ឌទី១ ច្បាប់ ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា/ឆ្នាំ២០១៤។

ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់តាមរយៈដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅកាន់ចៅក្រមជំនុំជម្រះតែម្តង ដោយមិនចាំបាច់មានការស៊ើបសួរក៏បាន។

**ខ. សមត្ថកិច្ចតាមដែនដី**

យើងដឹងហើយថាចៅក្រមស៊ើបសួរ ត្រូវតែមានស្ថិតនៅជាមួយសាលាដំបូងគ្រប់រាជធានីខេត្តទាំងអស់នៅទូទាំងប្រទេសកម្ពុជា។ ហេតុដូច្នេះហើយក្នុងនាមគាត់ជាអ្នកមានសមត្ថកិច្ចស៊ើបសួរ តែចំពោះបទល្មើសព្រហ្មទណ្ឌណាដែលបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។ យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការបញ្ញត្តិថា ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចតាមដែនដីគឺ[9]៖

- ចៅក្រមស៊ើបសួរនាទីកន្លែងប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់ រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នាហើយទទួលពាក្យបណ្តឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ហើយចំពោះទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីធ្វើការសម្រេច។ ចំណែកវិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល ដែលសេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**កថាខណ្ឌទី៤៖ គោលការណ៍នៃការស៊ើបសួរ**

គោលការណ៍ជាវិធានទូទៅ ឬទ្រឹស្តីមួយដែលផ្តល់នូវមូលដ្ឋាន ឬប្រភពដើមនៃបទដ្ឋានគតិយុត្ត។ ម្យ៉ាងវិញទៀតគោលការណ៍ក៏ជាវិធានគតិយុត្ត ដែលបង្កើតដោយអត្ថបទច្បាប់ណាមួយដែលមានលក្ខខណៈទូទៅក្នុងគោលបំណងជានាការអនុវត្តផ្សេងៗហើយមានតម្លៃគតិយុត្តខ្ពស់។[10]

យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌការស៊ើបសួរមានលក្ខណៈឬគោលការណ៍សំខាន់ៗដូចជា៖

- គោលការណ៍ការស៊ើបសួរត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ
- ការស៊ើបសួរត្រូវធ្វើឡើងជាការសម្ងាត់ ការរក្សាការសម្ងាត់នេះត្រូវតម្រូវឱ្យបុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរជាពិសេស ចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ច ដូចជាអ្នកជំនាញដែលមានចែងនៅក្នុងមាត្រា៩៥(ការត្រួតពិនិត្យខាងបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ត្រូវរក្សាការ

---

[9] មាត្រា ១២៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[10] ដកស្រង់ចេញពីវចនាក្រមតម្រាច្បាប់។

សម្លាត់នៃវិជ្ជាជីវៈហើយក្នុងករណីដែលបុគ្គលដូចបានរៀបរាប់ខាងលើនេះមានការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន[11]។

- មានតែព្រះរាជអាជ្ញាទេ ដែលអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ដែលអាចឱ្យមានការកែតម្រូវជាដើម[12]
- ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន[13]
- ការស៊ើបសួរត្រូវបានបើកដោយមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[14]។
- ការស៊ើបសួរមានទាំងការដាក់បន្ទុក និងដោះបន្ទុក[15]។
- ការស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់នៅអមជានិច្ច ទោះក្នុងករណីណាក៏ដោយក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ[16]។
- ដែនសមត្ថកិច្ចនៃការស៊ើបសួរត្រូវធ្វើឡើងនៅតាមសាលាជាន់ទាប ឬសាលាដំបូងរាជធានីខេត្តដែលមាននៅទូទាំងប្រទេស[17]។
- វត្តមានរបស់ព្រះរាជអាជ្ញាអាចមាននៅគ្រប់កិច្ចស៊ើបសួរ ជាពិសេសក្នុងការសួរចម្លើយជនត្រូវចោទ ក្នុងការសួរតទល់ និងក្នុងការស្តាប់ចម្លើយ[18]។
- ការស៊ើបសួរអាចធ្វើតាមបណ្តឹងរបស់ជនរងគ្រោះដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវិធី ដោយបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា[19] ។
- ហើយត្រូវតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបង់ប្រាក់តម្កល់ទុក ដោយផ្អែកលើធនធាន និងផលលំបាកនៃរឿងក្តីដែលអាចមើលឃើញមុន[20]។

---

[11] មាត្រា ១២១ ,ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[12] មាត្រា១២១,កថាខណ្ឌទី៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[13] មាត្រា ១២២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[14] មាត្រា ១២៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[15] មាត្រា ១២៧,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[16] មាត្រា ១៣៨,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[17] មាត្រា ១៣០,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[18] មាត្រា ១៣៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[19] មាត្រា ១៣៩,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[20] មាត្រា ១៤០,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

## កថាខណ្ឌទី៥៖ វិសមិតភាពការស៊ើបសួរ

ជាទូទៅវិសមិតភាព ជាភាពដែលមិនអាចមាន ឬប្រកបកិច្ចការចូលគ្នាបាន។ ជាក់ស្តែង វិសមិតភាពរវាងមុខនាទីជាសមាជិកសភា និងរដ្ឋមន្ត្រីក្នុងពេលជាមួយគ្នា(នៅក្នុងប្រទេសខ្លះ)។ ម្យ៉ាងវិញទៀតភាពដែលប្តី និងប្រពន្ធមិនអាចរស់នៅជាមួយគ្នាជាប្តីប្រពន្ធបាន (ដោយយោងតាមវចនានុក្រមតម្រាច្បាប់)។

យោងតាមប្រសាសន៍របស់ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ឱ្យដឹងថា “វិសមតិភាពរវាងមុខងារស៊ើបសួរ និងមុខងារជំនុំជម្រះនេះគឺមានគោលដៅតែមួយដើម្បីធានាការកាត់ក្តីប្រកបដោយយុត្តិធម៌ ស្វែងរកនូវការពិតកាន់តែមានភាពសុក្រឹត ព្រោះមូលហេតុនេះនៅពេលចៅក្រមស៊ើបសួរបានធ្វើការស៊ើបសួរចប់សព្វគ្រប់ បើសិនជាចៅក្រមស៊ើបសួរបានបិទបញ្ចប់ការស៊ើបសួររបស់គាត់ ដោយគិតថារឿងក្តីនោះជននោះមានពិរុទ្ធ ដូច្នេះត្រូវបញ្ជូនជននោះទៅសវនាការដើម្បីជំនុំជម្រះ បើរឿងឧក្រិដ្ឋបច្ចុប្បន្នក្រមរបស់យើងកំណត់យកសមាសភាពចៅក្រមចំនួនដល់ទៅបីរូបដើម្បីធានាបន្ថែមទៀត ហើយនៅពេលបញ្ជូនគាត់ ទៅសវនាការជំនុំជម្រះចាប់ផ្តើមគិតពិចារណាថា សវនាការគឺមានគោលដៅធំមួយទៀតដើម្បីពិភាក្សាសម្ងិចឱ្យឃើញរកការពិតឱ្យកាន់តែច្បាស់ អីចឹងបានជានៅក្នុងដំណាក់កាលនេះបើយើងមិនបែងចែកមុខងារស៊ើបសួរជាមួយមុខងារជំនុំជម្រះទេ យើងឃើញថានៅពេលដែលគាត់ទៅជំនុំជម្រះបើឱ្យគាត់ជាអ្នកកាត់សេចក្តីថា តើជននោះមានពិរុទ្ធ ឬមួយក៏អត់ទេ គឺច្បាស់ភាគច្រើននៃករណីនេះគឺគាត់ប្រាកដថាមានពិរុទ្ធហើយ ព្រោះគាត់ជាអ្នកស៊ើប បានន័យថា ប្រសិនបើយើងអនុញ្ញាតឱ្យគាត់ចូលទៅជាចៅក្រមជំនុំជម្រះ ឬចូលរួមនៅក្នុងសមាសភាពនៃចៅក្រមជំនុំជម្រះក្នុងករណីគាត់មានបុរេវិនិច្ឆ័យរួចជាស្រេចថាជននោះមានពិរុទ្ធ អីចឹងធ្វើឱ្យសវនាការនោះមិនអាចបំពេញគោលដៅមួយស្វែករកនូវការពិតបានទេ ដូច្នេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិពីវិសមតិភាពរវាងមុខងារស៊ើបសួរ និងមុខងារជំនុំជម្រះនេះឡើង”។

យោងតាមការបកស្រាយខាងលើឃើញវិសមតិភាពរបស់ចៅក្រមស៊ើបសួរនៅក្នុងរឿងព្រហ្មទណ្ឌរួមមាន៖

- វិសមតិភាពរវាងមុខងារស៊ើបសួរ និងមុខងារជំនុំជម្រះ ដែលជាគោលការណ៍ចៅក្រមស៊ើបសួរមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងព្រហ្មទណ្ឌដែលខ្លួនបានចាត់ការ ក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើពុំដូច្នេះទេការជំនុំជម្រះត្រូវចាត់ទុកជាមោឃៈ[21]។
- វិសមិតភាពជាមួយការបំពេញមុខងារសាធារណៈ មុខងារជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬមុខងារជាទីប្រឹក្សាគ្រប់ឋានានុក្រម លើកលែងតែមានបទបញ្ញត្តិផ្ទុយពីនេះ[22]។

[21] មាត្រា ៥៥,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[22] មាត្រា ១០៦ កថាខណ្ឌទី១ ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាលេខ នស រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា/ឆ្នាំ២០១៤។

- វិសមិតភាពជាមួយការបំពេញមុខងារជាមេធាវី មុខរបរពាណិជ្ជកម្ម ឬធ្វើសកម្មភាពណាមួយផ្សេងទៀត ដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ឬប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម ប៉ុន្តែចៅក្រម និងព្រះរាជអាជ្ញាអាចបំពេញមុខងារជាគ្រូឧទ្ទេសនាមតាមគ្រឹះស្ថានសិក្សាបាន[23]។

## ផ្នែកទី២៖ នីតិវិធីនៃការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

### កថាខណ្ឌទី១៖ ការទទួលពាក្យបណ្ដឹង

ដំណាក់កាលចៅក្រមស៊ើបសួរ ជាដំណាក់កាលដែលស្វែងរកនូវការពិតជូនគ្រប់ភាគី។ ហើយអាចបើកឱ្យមានការស៊ើបសួរតាមដំណើរការបាន លុះត្រាតែមានការដាក់ពាក្យបណ្ដឹងមក ដែលពាក្យបណ្ដឹងនោះដោយផ្អែកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

### ក. សេចក្ដីសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរដោយព្រះរាជអាជ្ញា

ជាគោលការណ៍នៃការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់ព្រះរាជអាជ្ញា ស្របតាម(មាត្រា១២៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានការចង្អុលបង្ហាញប្រាប់ឈ្មោះ ឬប្រឆាំងនឹងអញ្ញាតជន ជនដែលមិនទាន់បានស្គាល់ឈ្មោះ[24]។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះនិទ្ទេសរួមមាន[25]៖

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន
- ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ដែលទម្រង់នេះមានលក្ខណៈដាច់ខាតជាវិធានការដែលត្រូវគោរព បើពុំដូច្នេះទេដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។

### ខ. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយខ្លួនឯងផ្ទាល់ ឬដោយមេធាវីក្នុងនាមជាជនរងគ្រោះ[26]។

---

[23]មាត្រា១០៦,កថាខណ្ឌទី២,ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា លេខនស/រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា,ឆ្នាំ២០១៤។

[24]មាត្រា៤៤,កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[25]មាត្រា៤៤,កថាខណ្ឌទី៣,ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខនស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧។

[26] មាត្រា ១៣៨ ,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ទោះបីជាចៅក្រមស៊ើបសួរទទួលបណ្តឹងពីជនរងគ្រោះ ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏ចៅក្រមស៊ើបសួរត្រូវតែទទួលបាននូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីតំណាងអយ្យការជាមុនសិន ទើបអាចធ្វើការស៊ើបសួរបាន។ ក្នុងន័យនេះដែរ ក្រោយពីទទួលបានបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរធ្វើការសម្គាល់នូវការដាក់ពាក្យបណ្តឹងមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីការួច ហើយចៅក្រមស៊ើបសួរបញ្ជូនពាក្យបណ្តឹងនេះទៅព្រះរាជអាជ្ញាដើម្បីឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋាន[27]។ ពេលដែលទទួលបានការបញ្ជូននេះ ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយការបើកការស៊ើបសួរនេះអាចធ្វើប្រឆាំងនឹងអញ្ញាតជន ឬចោទប្រកាន់ទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ ប៉ុន្តែព្រះរាជអាជ្ញាក៏អាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរប្រសិនបើបណ្តឹងអាជ្ញាត្រូវផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។

គួរកត់សម្គាល់ផងដែរថា បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាប្រភេទបណ្តឹងថ្មីដែលទើបតែបញ្ចូលនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះ ហើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវតម្រូវឱ្យធ្វើការបង់ប្រាក់តម្កល់ទុក ដោយផ្អែកលើធនធាន និងផលលំបាកនៃរឿងក្តីដែលអាចមើលឃើញមុន ដោយចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលត្រូវបង់ផងដែរ។ តែក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់នេះបាន។ ប្រសិនបើចៅក្រមស៊ើបសួរតម្រូវឱ្យបង់ប្រាក់តម្កល់ទុក តែដើមបណ្តឹងពុំព្រមបង់ក្នុងរយៈពេលកំណត់ដោយចៅក្រមទេ ចៅក្រមស៊ើបសួរត្រូវប្រកាសថាមិនអាចទទួលពាក្យបណ្តឹងនេះបានទេ[28]។ ការតម្រូវឱ្យបង់ប្រាក់តម្កល់ទុក គឺដើម្បីធានាការបង់ប្រាក់ពិន័យរដ្ឋប្បវេណី ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភបំពាន ឬបណ្តឹងមានការអូសបន្លាយពេលវេលា ដោយចៅក្រមស៊ើបសួរចេញដីកាសម្រេចឱ្យដើមបណ្តឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី[29]។

**កថាខណ្ឌទី២៖ អានុភាពនៃបណ្តឹងទទួលបានតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា**

អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តធិការជំនុំជម្រះ។[30] ការចោទប្រកាន់ដែលធ្វើឡើងដោយតំណាងអយ្យការ ក្នុងការបើកឱ្យមានការស៊ើប

[27] មាត្រា ១៣៩, ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[28] មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[29] មាត្រា ១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[30] មាត្រា៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

សួរ គឺធ្វើឡើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលនៅក្នុងដីកាបានចែងអំពីការចោទប្រកាន់ ព្រមទាំងបទល្មើសដែលត្រូវចោទប្រកាន់ទៅលើបុគ្គលណាមួយនៅក្នុងសេចក្តីសន្និដ្ឋាន។

**ក. ភាពមិនអាចធ្វើការដកបណ្តឹងបាន**

ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង និងពាក្យបរិហារដែលខ្លួនទទួលបានដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយបាន។ មុននឹងសម្រេច ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។[31] ក្នុងករណីដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ព្រះរាជអាជ្ញានឹងធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលនាំឱ្យកើតមានបណ្តឹងអាជ្ញា។ នៅពេលដែលមាន បណ្តឹងអាជ្ញាបានទៅដល់ចៅក្រមស៊ើបសួរហើយ ពាក្យបណ្តឹងមិនអាចដកវិញបានទេ។ ព្រះរាជអាជ្ញាដែលមានសិទ្ធិក្នុងការចាត់ការ ឬបញ្ជាមន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើការស៊ើបអង្កេតទៅលើបទល្មើសនោះទៀតដែរ ធ្វើយ៉ាងណារក្សានូវវិសាលភាពនៃបណ្តឹងក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ មួយវិញទៀត នៅក្នុងសេចក្តីសន្និដ្ឋានដែលព្រះរាជអាជ្ញាបានធ្វើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបញ្ជូនមកដល់ចៅក្រមស៊ើបសួរនោះមិនអាចធ្វើការបន្ថែមទៅលើសេចក្តីសន្និដ្ឋាននោះទៀតទេ។

**ខ.ភាតព្វកិច្ចចំពោះការស៊ើបសួរ**

នៅពេលដែលចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹង ចៅក្រមនោះត្រូវតែធ្វើការស៊ើបសួរទៅលើសំណុំរឿងនោះ។ ពោលគឺចៅក្រមស៊ើបសួរមិនអាចធ្វើការច្រានចោលក្នុងការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយសំអាងថារឿងនោះពុំមានប្រយោជន៍ ដោយធ្លាប់ឆ្លងកាត់ការស៊ើបសួរហើយម្តង ឬសំណុំរឿងមិនអាចមានលទ្ធផលក្នុងការស៊ើបសួរ។ ប៉ុន្តែចៅក្រមស៊ើបសួរ អាចមើលទៅលើសមត្ថកិច្ចដែនដី និងសមត្ថកិច្ចសម្ភារៈ។

**កថាខណ្ឌទី៣៖ វិសាលភាពនៃការស៊ើបសួរ**

យោងទៅលើសមត្ថកិច្ចដែលចងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរពុំអាចស៊ើបសួរទៅលើអង្គហេតុ ដែលពុំមាននៅក្នុងដីកាសន្និដ្ឋាននេះឡើយ។ ចៅក្រមស៊ើបសួរក៏ពុំមានតួនាទីស៊ើបសួរលើបណ្តឹងណាដាច់ខាត ទោះបីខ្លួនបានទទួលពាក្យបណ្តឹងដោយផ្ទាល់ក៏ដោយ គឺត្រូវបញ្ជូនបណ្តឹងនោះទៅឱ្យព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់ជាមុនសិន។ អនុលោមតាមមាត្រា១២៥ កថាខណ្ឌទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែអំពីអង្គហេតុនោះ

[31] មាត្រា៤០,កថាខណ្ឌទី១និងទី២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ខែសីហាឆ្នាំ២០០៧។

ប៉ុណ្ណោះ"។ ត្រង់ចំណុចនេះបានបង្ហាញឱ្យឃើញថា វិសាលភាពនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរដោយផ្អែកតែទៅតាមអង្គហេតុតែម្យ៉ាង។ ដែលការចែងបែបនេះអាចឱ្យយើងយល់ឃើញថា ចៅក្រមស៊ើបសួរមិនមានកាតព្វកិច្ចត្រូវសម្រេចតាមការវាយតម្លៃ ឬការកំណត់បទល្មើសដោយព្រះរាជអាជ្ញាដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ ពោលគឺចៅក្រមស៊ើបសួរមានសេរីភាពពេញលេញ ក្នុងការកំណត់បទល្មើសផ្សេងពីការកំណត់បទល្មើសដោយព្រះរាជអាជ្ញាកុំឱ្យតែការកំណត់បទល្មើសនោះទាក់ទង និងអង្គហេតុថ្មីដែលពុំមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា អង្គហេតុដែលប្តឹងមកចៅក្រមស៊ើបសួរ ជាបទល្មើសផ្សេងពីការកំណត់បទល្មើសដោយព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចដាក់ឱ្យជនត្រូវចោទនោះស្ថិតនៅក្រមការពិនិត្យក្នុងបទល្មើសផ្សេង ឬក៏បញ្ជូនជនត្រូវចោទនោះទៅកាន់តុលាការដើម្បីជំនុំជម្រះពីបទល្មើសដែលខ្លួនយល់ឃើញថាត្រឹមត្រូវនឹងអង្គហេតុផ្អែកតាមដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។

ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ហើយប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ[32]។ ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង[33]។ ម៉្យាងវិញទៀតក្នុងករណីចៅក្រមស៊ើបសួររកឃើញថាមានតម្រុយថ្មី ហើយពុំទាន់មាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ជនសង្ស័យដែលចៅក្រមស៊ើបសួរយល់ឃើញថាមានតម្រុយពិរុទ្ធភាពពាក់ព័ន្ធទៅនឹង ការប្រព្រឹត្តបទល្មើសនោះ រួចចៅក្រមស៊ើបសួរត្រូវបញ្ជូនព័ត៌មានអំពីតម្រុយថ្មីនេះទៅព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់។

[32] មាត្រា ១២៥,កថាខណ្ឌទី២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[33] មាត្រា ១២៥,កថាខណ្ឌទី៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

# ជំពូកទី២
# ការស្រាវជ្រាវ និងវិធានការនិរន្តរាយ
# របស់ចៅក្រមស៊ើបសួរ

# ជំពូកទី២

# ការស្រាវជ្រាវ និងវិធានការនិរន្តរាយរបស់ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖ អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌបានឱ្យដឹងថា ចៅក្រមស៊ើបសួរគាត់មានអំណាចច្រើនក្នុងការបង្ហាញភស្តុតាងដល់តុលាការចំពោះរឿងក្តីណាមួយដែលគាត់ទទួលបន្ទុក។ ដើម្បីជានាឱ្យឃើញនូវភាពត្រឹមត្រូវការពិត តម្លាភាព និងយុត្តិធម៌ ពោលគឺដើម្បីធ្វើការស្វែងរកឱ្យឃើញនូវពិរុទ្ធភាពនៃបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ លើសពីនេះទៅទៀតចៅក្រមស៊ើបសួរគាត់មានអំណាចក្នុងការស្រាវជ្រាវរកបន្ថែមនូវភស្តុតាងដោយខ្លួនឯងក៏បាន ឬក៏គាត់អាចធ្វើការផ្ទេរសំណុំរឿងនេះទៅឱ្យចៅក្រមស៊ើបផ្សេងទៀត ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបជំនួសនៅពេលដែលចៅក្រមទទួលបន្ទុកនូវសំណុំរឿងនោះគាត់ពុំមានលទ្ធភាពក្នុងការបំពេញភារកិច្ចនេះបានត្រឹមត្រូវ។

### កថាខណ្ឌទី១៖ វិធីសាស្ត្រនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

នៅក្នុងដំណាក់កាលនៃដំណើរការស៊ើបសួរ ចៅក្រមស៊ើបសួរមានអំណាចជាច្រើនក្នុងការស្រាវជ្រាវចំពោះអង្គហេតុរួមមាន ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការស្តាប់ចម្លើយសាក្សី ការចុះទៅដល់ទីកន្លែងកើតហេតុ ការឆែកឆេរ និងចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ ការស្តាប់ទូរស័ព្ទ និងថតការសន្ទនា ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ

#### ក. ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ចៅក្រមស៊ើបសួរ ត្រូវតែដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ នូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ហើយចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត។[34] ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យបាននៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជនត្រូវចោទនេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះ ត្រូវចុះនៅក្នុងកំណត់ហេតុ នៅពេលចូលបង្ហាញខ្លួនលើកដំបូង។[35] ប្រសិនបើ

[34] មាត្រា ១២៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[35] មាត្រា ១៤៣,កថាខណ្ឌទី១,ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ជនត្រូវចោទចង់ឆ្លើយ នោះចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីខ្លួនដោយអនុវត្តតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។[36] ជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេមេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។[37]

ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា[38]៖

- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ នៅពេលណាដែលខ្លួនផ្លាស់ប្ដូរអាសយដ្ឋាន
- គ្រប់ការឱ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះ ត្រូវចាត់ថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់។

ការឱ្យដំណឹង ព្រមទាំងការប្រកាសស្ដីពីការផ្លាស់ប្ដូរអាសយដ្ឋាននោះត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។[39] ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ។ អ្នកបកប្រែត្រូវធ្វើសម្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួន ថាខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាលកងរាជអាវុធហត្ថ ភាគី ឬសាក្សីទេ។[40]

**ខ. ការសួរចម្លើយជនត្រូវចោទ**

នៅពេលដែលជនត្រូវចោទចូលមកបង្ហាញខ្លួនលើកដំបូងចៅក្រមស៊ើបសួរត្រូវចាត់វិធានការដូចជា ត្រូវពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជនត្រូវចោទនេះឱ្យបានដឹងអំពីបទចោទប្រកាន់ និងពន្យល់អំពីធាតុផ្សំតាមផ្លូវច្បាប់អំពីឈ្មោះនៃបទល្មើសដែលបានត្រូវចោទប្រកាន់។ ហើយនៅក្នុងនាមជាចៅក្រមស៊ើបសួរត្រូវប្រាប់អំពីគោលការណ៍ដល់ជនត្រូវចោទថាខ្លួនអាចមានសិទ្ធិក្នុងការឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ តែក្នុងករណីនេះត្រូវតែមានការចុះក្នុងនិទ្ទេស ស្ដីពីការប្រាប់នេះក្នុងកំណត់ហេតុនៅពេលដែលចូលមកបង្ហាញខ្លួនលើកដំបូង។ ការសួរចម្លើយជនត្រូវចោទនេះដែរ គឺដើម្បីឱ្យទទួលបានព័ត៌មានដែលពាក់ព័ន្ធនឹងបទល្មើសបានកើតឡើង ហើយវាក៏ជាឱកាសឱ្យជនត្រូវចោទធ្វើការបំភ្លឺឱ្យបានច្បាស់អំពីអង្គហេតុណាមួយ ព្រមទាំងអាចសង្កេត

[36] មាត្រា ១៤៣,កថាខណ្ឌទី២,ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[37] មាត្រា ១៤៣,កថាខណ្ឌទី៣,ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[38] មាត្រា ១៤៣,កថាខណ្ឌទី៤,ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[39] មាត្រា ១៤៣,កថាខណ្ឌទី៥,ក្រមនីតិវិធីព្រហ្មទណ្ឌ ,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[40] មាត្រា ១៤៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

អំពីបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទបន្ថែមផងដែរ។ ចៅក្រមស៊ើបសួរក៏ត្រូវប្រាប់ផងដែរដល់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដែលក្នុងករណីជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។[41]

ក្នុងការសួរចម្លើយនេះ កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅមេធាវីមុនយ៉ាងតិច៥(ប្រាំ) ថ្ងៃមុនពេលសួរចម្លើយមកដល់ ដើម្បីឱ្យមេធាវីមានពេលត្រៀមគ្រប់គ្រាន់ក្នុងការពិនិត្យមើលទៅលើសំណុំរឿងនៃនីតិវិធីនេះ។ ហើយជនត្រូវចោទអាចត្រូវធ្វើការសួរចម្លើយដោយចៅក្រមស៊ើបសួរបានតែចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ តែមិនបានចូលមកបង្ហាញខ្លួននៅថ្ងៃ និងតាមម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីពីការអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។ លើកលែងតែមានករណីពិសេស ឬប្រសិនបើជននោះបានបោះបង់សិទ្ធិរបស់ខ្លួនក្នុងការដែលត្រូវមានមេធាវី។ ប្រសិនបើការសួរចម្លើយជនត្រូវចោទបានធ្វើឡើងដោយពុំមានវត្តមានមេធាវី កំណត់ចំណាំនៃការបោះបង់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៃការសួរចម្លើយជាលាយលក្ខណ៍អក្សរ។[42] ការសួរចម្លើយនេះត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរ ទោះបីជាយ៉ាងនេះក្តី ព្រះរាជអាជ្ញា និងមេធាវីដទៃទៀត ក៏អាចសាកសួរបានដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ការសួរតទល់គ្នាក៏អាចធ្វើបានផងដែរក្នុងដំណាក់កាលនៃការសួរចម្លើយនេះ។[43]

ក្នុងរយៈពេល៤(បួន)ខែបានកន្លងផុតទៅ គិតចាប់ពីពេលសួរចម្លើយលើការបង្ហាញខ្លួនលើកដំបូង ជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ដូច្នេះចៅក្រមស៊ើបសួរត្រូវតែទទួលយកចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងចិរវេលា១(មួយ)ខែបន្ទាប់ពីការសុំទេ នោះជនត្រូវចោទអាចប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯងបាន បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។[44]

គួរបញ្ជាក់ផងដែរថា កាលណាជនត្រូវចោទត្រូវបានជាប់ឃុំ មេធាវីដែលជាអ្នកតំណាង មានសិទ្ធិក្នុងការប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ការសន្ទនារបស់មេធាវី

---

[41] មាត្រា ១៤៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[42] មាត្រា ១៤៥,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[43] មាត្រា ១៤៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[44] មាត្រា ១៤៨,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

និងជនត្រូវចោទមិនត្រូវគេស្តាប់ ឬថតបានទេ។ ហើយមេធាវីអាចអានលិខិតនៃសំណុំរឿងក្តីឱ្យកូនក្តីរបស់ខ្លួនស្តាប់បាន ផ្ទុយទៅវិញមេធាវីមិនអាចឱ្យលិខិតថតចម្លងពីលិខិតសំណុំរឿងក្តីនេះទៅឱ្យកូនក្តីខ្លួនបានឡើយ។[45]

**គ. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃការស៊ើបសួរ។ ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលជំនួយពីមេធាវីអមក្នុងពេលកំពុងស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរ។ ដូច្នេះមេធាវីត្រូវទទួលការកោះហៅក្នុងថេរវេលា៥(ប្រាំ)ថ្ងៃ មុនការស្តាប់ចម្លើយដើម្បីមានសិទ្ធិ និងពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យមើលសំណុំរឿងក្នុងចិរវេលានេះ និងអាចទទួលបាននូវឯកសារចម្លង និងលិខិតផ្សេងៗនៃនីតិវិធី ដោយធ្វើការរ៉ាប់រងសោហ៊ុយដោយខ្លួនឯង ដែលមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។[46]

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមការកំណត់ទេ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានរបស់មេធាវីបាន ដោយគ្រាន់តែមានការចុះនិទ្ទេសស្តីពីអវត្តមាននេះនៅក្នុងកំណត់ហេតុការស្តាប់ចម្លើយ។[47]

ក្នុងករណីពិសេសចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយមិនបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់ចោលនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែក ពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី។ ហើយនៅក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចធ្វើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីភ័យខ្លាចបាត់បង់តម្រុយភស្តុតាង។ ដែលប្រភេទបន្ទាន់នេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[48]

**ឃ. ការស្តាប់ចម្លើយសាក្សី**

សាក្សីជាបុគ្គលដែលត្រូវបានតុលាការកោះហៅមកសាកសួរនូវហេតុការណ៍ ដែលមានផលប្រយោជន៍ដល់ការវិនិច្ឆ័យរឿងក្តី។ ហើយសាក្សីនេះមានពីរប្រភេទទៀត ទាំងសាក្សីដោះបន្ទុក និងសាក្សីដាក់បន្ទុក។ នៅក្នុងដំណាក់កាលស៊ើបសួរ ការស្តាប់ចម្លើយសាក្សីរបស់ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែល

---

[45] មាត្រា ១៤៩,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[46] មាត្រា១៥០,កថាខណ្ឌទី១,ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខនស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[47] មាត្រា១៥០,កថាខណ្ឌទី៣,ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខនស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[48] មាត្រា១៥០,កថាខណ្ឌទី៣ ,៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ចម្លើយទាំងនោះ អាចមានប្រយោជន៍នៅក្នុងការសម្តែងឱ្យឃើញការពិត ដោយពុំមានវត្តមានរបស់ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ លើសពីនេះចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានដែរ។ បុគ្គលទាំងឡាយណាដែលត្រូវបានកោះហៅដោយចៅក្រមស៊ើបសួរអាចត្រូវបានបង្ខំឱ្យចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ នៅពេលដែលសាក្សីណាមួយខកខានមិនចូលមកបង្ហាញខ្លួន ចៅក្រមស៊ើបសួរអាចចេញបញ្ជាឱ្យចូលបង្ហាញខ្លួនដែលអនុញ្ញាតឱ្យកងកម្លាំងសាធារណៈចាប់ និងនាំខ្លួនសាក្សីនោះមកកាន់តុលាការបាន។[49]

ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីបានក្រោយពីឱ្យសាក្សីស្បថ ព្រោះថាការសម្បថបានធ្វើឡើងស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិតតែប៉ុណ្ណោះ។[50] ការសម្បថរបស់សាក្សីអាចអនុញ្ញាតឱ្យរួចពីសម្បថកាលបើបុគ្គលដែលមានភាពជិតស្និទ្ធជាមួយជនត្រូវចោទ ដូចជា[51]៖

- ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ
- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ
- បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ
- បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ
- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ
- កុមារអាយុតិចជាង១៤ឆ្នាំ។

ម្យ៉ាងវិញទៀតដើម្បីគោរពសិទ្ធិការពារខ្លួនរបស់សាក្សី ចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី និងបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ គ្រាន់តែជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានហើយ។ ប្រសិនបើសាក្សីនោះឈឺ ឬមិនអាចធ្វើដំណើរបានចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះនៅដើម្បីទទួលចម្លើយ។[52] ប៉ុន្តែអ្វីដែលសំខាន់នោះ រាល់ការស្តាប់ចម្លើយគ្រប់សាក្សីដែលចៅក្រមស៊ើបសួរមានជំនួយការរបស់ខ្លួន នោះគឺក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុអំពីការស្តាប់ចម្លើយនោះជាដាច់ខាតផងដែរ។

---

[49] មាត្រា ១៥៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[50] មាត្រា១៥៤,កថាខណ្ឌទី១,ក្រមនីតិវិធីព្រហ្មទណ្ឌ ,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[51] មាត្រា ១៥៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[52] មាត្រា១៥៧ និងមាត្រា១៥៨,ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**ខ. ការចុះទៅដល់ទីកន្លែងកើតហេតុ**

ការចុះដល់កន្លែងកើតហេតុនេះ ធ្វើឡើងដើម្បីធ្វើការឆ្លើយតបទៅនឹងគោលដៅតែមួយដូចក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ដែរ ដូចជាការពិនិត្យកត់ត្រា ផ្គុំអង្គហេតុឡើងវិញ ធ្វើការឆែកឆេរ ឬបំពេញគ្រប់កិច្ចស៊ើបសួរផ្សេងៗទៀត។ ដែលករណីនេះចៅក្រមស៊ើបសួរអាចធ្វើការចុះទៅដល់កន្លែងកើតហេតុជាមួយក្រឡាបញ្ជីនៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង។

ក្នុងករណីដែលចៅក្រមស៊ើបសួរធ្វើការចុះទៅដល់ទីកន្លែងកើតហេតុនេះ តម្រូវឱ្យមានការជូនដំណឹងទៅដល់ព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ។ ក្នុងការណ៍នេះព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរបានផងដែរ។ ប្រសិនបើចាំបាច់នៃការស៊ើបសួរតម្រូវ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងកើតហេតុជាមួយក្រឡាបញ្ជីនៅលើវិសាលភាពដែនដីជាតិទាំងមូល។ ប៉ុន្តែចៅក្រមត្រូវធ្វើការជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូងនៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ដែលករណីនេះចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីអំពីប្រតិបត្តិការរបស់ខ្លួនផងដែរ។[53]

**ច. ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ការឆែកឆេរ គឺជាសិទ្ធិក្នុងការស្រាវជ្រាវអំពីធាតុនៃវត្ថុតាង អំពីការប្រព្រឹត្តបទល្មើសណាមួយ។ ចំណែកការចាប់យកវត្ថុតាង គឺជាសិទ្ធិក្នុងការយកវត្ថុ ឬឯកសារមកដាក់ក្រោមវិធានយុត្តិធម៌ដោយមានការធ្វើជាបញ្ជីសារពើភ័ណ្ឌ និងបិទស្លាកបោះត្រាលើវត្ថុតាងនោះ។

ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន។ ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី២(ពីរ)នាក់ ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ ចៅក្រមស៊ើបសួរមិនអាចផ្តើមឆែកឆេរមុនម៉ោង៦(ប្រាំមួយ)ព្រឹក និងក្រោយម៉ោង១៨(ដប់ប្រាំបី)ល្ងាចបានឡើយ។ ប៉ុន្តែមានករណីលើកលែងមួយចំនួនដូចជា ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន និងក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។

ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី២(ពីរ)នាក់។ ហើយរាល់កំណត់ហេតុត្រូវចុះនិទ្ទេសអំពី

[53] មាត្រា ១៣០,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ ម្យ៉ាងវិញទៀតកាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវីនេះ។[54]

នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចនេះត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹង និងមេធាវីនៃអ្នកប្ដឹងប្រសិនបើមាន។ ការសងវត្ថុមិនត្រូវប្រគល់ទៅឱ្យអ្នកដែលប្ដឹងសុំនោះទេ កាលណាបើវិធានការនេះអាចបង្កជាឧបសគ្គដល់ការសម្ដែងឱ្យឃើញការពិត។ ចំពោះវត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួនបានទេ។ ហើយវត្ថុទាំងនេះ ត្រូវរឹបអូសមកធ្វើជាកម្មសិទ្ធិរដ្ឋ។[55]

**ឆ. កោសលវិច័យ**

នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ដើម្បីជាផលប្រយោជន៍ដល់ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរក្នុងការស្វែងរកការពិតនៃអង្គហេតុ ហើយច្បាប់ក៏បានធ្វើការអនុញ្ញាតឱ្យចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យអ្នកមានជំនាញធ្វើកោសលវិច័យដោយធ្វើការវិភាគ និងបញ្ជាក់លទ្ធផលដោយអ្នកជំនាញ។ ព្រោះករណីខ្លះចៅក្រមស៊ើបសួរមិនអាចធ្វើការវាយតម្លៃដោយខ្លួនឯងបានទេ ជាក់ស្តែងក្នុងរឿងប្រភេទគ្រឿងញៀន សាកសព ការកំណត់ប្រភេទឈាម ប្រភេទអាវុធ ឬឧបករណ៍ផ្សេងៗដែលប្រើប្រាស់សម្រាប់ការប្រព្រឹត្តបទល្មើស។ ដូច្នេះហើយភាពចាំបាច់នៃការធ្វើកោសលវិច័យនេះ វាពិតជាអាចធ្វើឱ្យយើងរកឃើញ ឬអាចឱ្យយើងប្រើប្រាស់សញ្ញាសម្គាល់មួយចំនួន ឬភស្តុតាងផ្សេងៗដោយសារមធ្យោបាយបច្ចេកទេស និងវិទ្យាសាស្ត្រមួយចំនួនទៀតផងដែរ។

ក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិនិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញពីព្រះរាជអាជ្ញា និង ១(មួយ)ខែ ប្រសិនបើពាក្យនោះចេញពីជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្ដឹងសុំជាបន្ទាន់។[56] ការធ្វើកោសលវិច័យក្នុងរឿងព្រហ្មទណ្ឌត្រូវបានបង្កើតឱ្យមានបញ្ជីថ្នាក់ជាតិមួយនៃអ្នកជំនាញ បញ្ជីនេះត្រូវបាន

[54] មាត្រា ១៥៩,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[55] មាត្រា ១៦១,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[56] មាត្រា ១៦២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

រៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប៉ុន្តែបែបបទនៃការចុះឈ្មោះ ឬលុបឈ្មោះចេញពីបញ្ជីត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ អ្នកជំនាញដែលត្រូវបានចុះនៅក្នុងបញ្ជីថ្នាក់ជាតិត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។ អ្នកជំនាញត្រូវបានចុះឈ្មោះក្នុងបញ្ជី មិនចាំបាច់ស្បថសាជាថ្មីទេនៅពេលណាខ្លួនត្រូវបានចាត់តាំងឱ្យធ្វើកោសលវិច័យ។[57]

ចៅក្រមស៊ើបសួរ តាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងថ្នាក់ជាតិនៃអ្នកជំនាញ។ ចៅក្រមស៊ើបសួរចេញដីកាដោយមានសំអាងហេតុ ពិសេសអាចចាត់តាំងអ្នកជំនាញដែលគ្មានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិបាន។ ករណីនេះអ្នកជំនាញត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។[58] អ្នកជំនាញត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ។ ដីកាត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះ ហើយបេសកកម្មអាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។ ប្រសិនបើជាការគួរ ចៅក្រមស៊ើបសួរប្រគល់វត្ថុដែលចាប់បានមួយផ្នែក ឬទាំងអស់នោះជូនអ្នកជំនាញ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុដែលចាប់បាន។ អ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសលវិច័យបាន ប្រសិនបើកោសលវិច័យនេះអាចធ្វើឱ្យខូចខាត ឬវិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះមុននឹងចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន។[59]

អ្នកជំនាញបំពេញបេសកកម្មរបស់ខ្លួន ក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ។ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តទៅនៃបេសកកម្មរបស់ខ្លួនជាអាទិ៍ ការលំបាកដែលខ្លួនអាចជួបប្រទះ។ ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរអាចចាត់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ។ ប៉ុន្តែប្រសិនបើកាលៈទេសៈតម្រូវនោះចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឱ្យធ្វើការពន្យារពេលបាន។[60] ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ ហើយចម្លើយដែលអ្នកជំនាញបានទទួលនោះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតា។ បុគ្គលដែលអ្នកជំនាញស្តាប់ចម្លើយនោះមិនបាច់ស្បថទេ។ ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ត្រូវស្តាប់ចម្លើយជនត្រូវចោទ អ្នកជំនាញត្រូវសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ជនត្រូវចោទអាចសុំឱ្យ

---

[57] មាត្រា ១៦៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[58] មាត្រា ១៦៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[59] មាត្រា ១៦៥,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[60] មាត្រា ១៦៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

អ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួននៅចំពោះមុខមេធាវី។ ប៉ុន្តែកាលណាចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬអ្នកចិត្តសាស្ត្រពិនិត្យជនត្រូវចោទនោះ ការពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រត្រូវធ្វើដោយគ្មានវត្តមានមេធាវី។[61]

កាលណារបាយការណ៍នៃការធ្វើកោសលវិច័យត្រូវបានបញ្ចប់រួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវកោះហៅជនត្រូវចោទ និងមេធាវីដើម្បីប្រាប់ឱ្យដឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យនេះ។[62] ហើយចៅក្រមស៊ើបសួរអាចធ្វើការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីផងដែរដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ។[63] ចៅក្រមស៊ើបសួរត្រូវតែកំណត់រយៈពេលដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ។ រយៈពេលនេះមិនអាចតិចជាង១០(ដប់)ថ្ងៃទេ។ ក្នុងរយៈពេលនេះសំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យ អាចត្រូវបានពិនិត្យមើលដោយមេធាវី។[64] គ្រប់ពាក្យសម្តីកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យត្រូវតែមានសំអាងហេតុ និងធ្វើឡើងជាលាយលក្ខណ៍អក្សរ។[65]

កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង១(មួយ)ខែ ប្រសិនបើពាក្យនេះចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ហើយដីកានេះត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ។[66] គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ ដែលធ្វើឡើងក្រោយផុតរយៈពេល ដែលកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។[67] ប្រសិនបើចៅក្រមស៊ើបសួរដែលបានទទួលពាក្យសុំឱ្យធ្វើកោសលវិច័យ ធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ មិនព្រមសម្រេចក្នុងរយៈពេលដែលមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា១៦២(ភាពចាំបាច់នៃការធ្វើកោសលវិច័យ)នៃក្រមនេះ ឬចែងក្នុងមាត្រានេះ អ្នកសុំអាចធ្វើពាក្យប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[68]

61 មាត្រា ១៦៧,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

62 មាត្រា១៧០,កថាខណ្ឌទី១,២,៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខនស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

63 មាត្រា១៧០,កថាខណ្ឌទី៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខនស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

64 មាត្រា១៧០,កថាខណ្ឌទី៥,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

65 មាត្រា១៧០,កថាខណ្ឌទី៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

66 មាត្រា ១៧០,កថាខណ្ឌទី៧,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

67 មាត្រា ១៧០,កថាខណ្ឌទី៨,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

68 មាត្រា ១៧០,កថាខណ្ឌទី៩,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

គួរបញ្ជាក់ផងដែរថារាល់សោហ៊ុយសម្រាប់ធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ។ ប៉ុន្តែបើកាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ស្នើសុំឱ្យធ្វើកោសលវិច័យ រួមទាំងកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យផ្សេងទៀត សោហ៊ុយទាំងអស់នេះជាបន្ទុករបស់រដ្ឋ។[69]

**៥. ការស្តាប់ទូរស័ព្ទ និងថតការសន្ទនា**

"បច្ចុប្បន្នភាពកាន់តែទំនើបលើប្រព័ន្ធបច្ចេកវិទ្យា សកម្មភាពប្រចាំថ្ងៃកាន់តែមានភាពឆាប់រហ័ស" ជាការពិតណាស់នៅក្នុងសង្គមយើងសព្វថ្ងៃការស្តាប់តាមទូរស័ព្ទ និងការថតការសន្ទនា ឬប្រើប្រាស់ផ្នែកណាមួយនៃប្រព័ន្ធអេឡិចត្រូនិច នៅក្នុងកាលៈទេសៈលំបាកណាមួយកើតឡើងពិតជាមានសារៈសំខាន់ណាស់ដើម្បីយកធ្វើជាភស្តុតាងបង្ហាញថាហេតុការណ៍ណាមួយថាត្រឹមត្រូវ ឬមិនត្រឹមត្រូវបាន។

ចំណែកនៅក្នុងប្រព័ន្ធតុលាការវិញនាពេលបច្ចុប្បន្ននេះ ការស្តាប់ទូរស័ព្ទនេះក៏ជាករណីពិសេសមួយសម្រាប់នៅដំណាក់កាលចៅក្រមស៊ើបសួរ ពេលអនុវត្តភារកិច្ចក្នុងការស្រាវជ្រាវដើម្បីស្វែងរកការពិតនៃអង្គហេតុដោយអនុលោមតាមច្បាប់កំណត់ជានិច្ច។ ដោយតាមតម្រូវការចាំបាច់ដើម្បីស្តែងឱ្យឃើញការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទបាន។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ផងដែរ ដូចជា សារតាមទូរសារ ឬសារតាមអ៊ីនធើណែត។[70] លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរ ក៏អាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថតបានដែរ ហើយក្នុងនាមជាចៅក្រមស៊ើបសួរនៃរឿងក្តីនោះក៏ត្រូវធ្វើការសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងធ្វើការកំណត់ផងដែរអំពីរយៈពេលនៃការបំពេញបេសកកម្មនោះ។[71]

ក្នុងនាមជាអង្គភាពសាធារណៈមន្ត្រីរាជការដែលចាត់តាំងត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរនៅក្នុងពេលអនុវត្តបេសកកម្ម ត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកកម្មជាអាទិ៍ អំពីការលំបាកណាមួយជាយថាហេតុ។ បន្ទាប់ពីបេសកកម្មត្រូវបានបំពេញរួចរាល់អស់ហើយ អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះត្រូវធ្វើការចម្លងសារសំឡេងការសន្ទនាទាំងអស់នោះជាលាយលក្ខណ៍អក្សរបាន។ ដែលការធ្វើជាលាយលក្ខណ៍អក្សរនេះត្រូវមានការឆ្លុះបញ្ចាំងឱ្យឃើញនូវភាពត្រឹមត្រូវនូវខ្លឹមសារនៃសំឡេងដែលថតបាន មិនតែប៉ុណ្ណោះនោះទេ សំឡេងដែលថតបានត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ ព្រមទាំងបិទស្លាកសម្គាល់ឱ្យ

[69] មាត្រា ១៧១,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[70] មាត្រា១៧២,កថាខណ្ឌទី១,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[71] មាត្រា១៧២,កថាខណ្ឌទី២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

បានត្រឹមត្រូវ។[72] គួរបញ្ជាក់ផងដែរថា គ្រប់ពេលវេលាចៅក្រមស៊ើបសួរ អាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតការសន្ទនានោះបាន ព្រោះថាការចូលទៅក្នុងទីកន្លែងទាំងនេះមិនបានធ្វើការហាមឃាត់ដល់សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរនោះទេ មិនថាដោយមានសំអាងលើមូលហេតុអ្វីក៏ដោយ ទោះបីជាកន្លែងឃោជាក៏ដោយក៏ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការចូលរួមបេសកកម្មនេះបាន។ ហើយនៅក្នុងករណីខ្លះចៅក្រមស៊ើបសួរពុំអាចធ្វើបេសកកម្មនេះដោយខ្លួនគាត់ផ្ទាល់បានទេ ដោយសារមូលហេតុណាមួយ គឺគាត់នៅតែអាចធ្វើកិច្ចការនេះបានដោយមានចេញដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ។[73]

### កថាខណ្ឌទី២៖ ដីកាចាត់ឱ្យស៊ើបសួរជំនួស

នៅក្នុងដំណើរការ នៃការស៊ើបអង្កេតប្រសិនបើចៅក្រមស៊ើបសួរជួបប្រទះនូវឧបសគ្គណាមួយទាក់ទងទៅនឹងការស្វែងរកភស្តុតាង ដើម្បីឱ្យឃើញនូវការពិតនៃរឿងក្តី ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិទៅឱ្យបុគ្គលដែលមានសមត្ថកិច្ចក្នុងការស៊ើបសួរជំនួស ដោយចៅក្រមស៊ើបសួរគ្រាន់តែធ្វើការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស។

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរ អាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត ដល់មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរនេះ។[74] ដីកាចាត់ឱ្យស៊ើបសួរជំនួសគឺជាការបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅទេ ត្រូវណែនាំឱ្យបានច្បាស់លាស់។ ហើយចៅក្រមស៊ើបសួរ ត្រូវធ្វើការកំណត់ចិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានការចុះនូវកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរផ្ទាល់ និងមានការបោះត្រាបញ្ជាក់ផងដែរ។[75]

### កថាខណ្ឌទី៣៖ ការស្នើសុំបំពេញកិច្ច

យោងតាមស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌថ្មី បានផ្តល់សិទ្ធិក្នុងការស្នើសុំបំពេញកិច្ចអាចធ្វើឡើងតាមរយៈការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា ដែលជាអ្នកតំណាងឱ្យសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋ ផលប្រយោជន៍របស់អនីតិជន ការស្នើសុំបំពេញកិច្ចធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី និងការស្នើសុំបំពេញកិច្ចដោយជនត្រូវចោទ។

[72] មាត្រា១៧២,កថាខណ្ឌទី៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[73] មាត្រា១៧២,កថាខណ្ឌទី៤,៥,ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[74] មាត្រា១៧៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[75] មាត្រា១៧៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**ក. ការបំពេញកិច្ចដោយព្រះរាជអាជ្ញា**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរ ធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍បាន។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ នោះចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ហើយប្រសិនបើចៅក្រមស៊ើបសួរ មិនបានធ្វើការសម្រេចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនេះទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាព្រហ្មទណ្ឌស៊ើបសួរដែលសម្រេចជំនួសឱ្យចៅក្រមស៊ើបសួរ។[76]

**ខ.ការបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរឱ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់ ឬចុះទៅដល់ទីកន្លែងកើតហេតុបាន។ ពាក្យសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងចិរវេលា១(មួយ)ខែ ក្រោយពេលទទួលបានពាក្យបណ្តឹងសុំនេះ។ ចំពោះដីកាបដិសេធនេះត្រូវមានបញ្ជាក់នូវសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងចិរវេលា១(មួយ)ខែទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការដាក់ពាក្យបណ្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសឱ្យចៅក្រមស៊ើបសួរ។[77]

**គ.ការបំពេញកិច្ចដោយជនត្រូវចោទ**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែងកើតហេតុ។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា១(មួយ)ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងចិរវេលា១ (មួយ)ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលជាអ្នកសម្រេចជំនួសឱ្យចៅក្រមស៊ើបសួរ។[78]

[76] មាត្រា១៣២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[77] មាត្រា១៣៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[78] មាត្រា១៣៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

## ផ្នែកទី២៖ វិធានការនិរន្តរាយ

នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ កាលណាមានបទល្មើសណាមួយកើតឡើងដែលច្បាប់កំណត់ថាពិតជាបទល្មើសដែលបង្កឱ្យមាន ទោសព្រហ្មទណ្ឌពិតប្រាកដមែន គឺត្រូវតែមានវិធានអនុវត្តចំពោះទង្វើទាំងនោះបាន។

និរន្តរាយមានន័យថា ការមិនមានអន្តរាយ ដំណើរដែលគ្មានគ្រោះថ្នាក់។[79] ដែលវិធានការនៅទីនេះសំដៅដល់ការចេញដីការរបស់ចៅក្រមស៊ើបសួរ ដែលជាគោលការណ៍សំខាន់តម្រូវឱ្យគាត់មានអំណាចក្នុងការបញ្ជាឱ្យស្វែងរក និង បញ្ជាឱ្យចូលខ្លួនចំពោះបុគ្គលដែលជាជនត្រូវចោទ និងបុគ្គលដែលមានតម្រុយពិរុទ្ធភាពមិនព្រមឆ្លើយតបតាមការកោះហៅតែប៉ុណ្ណោះ។

### កថាខណ្ឌទី១៖ ការចេញដីកា

ដីកាជាបញ្ជា ឬ សេចក្ដីបង្គាប់ជាលាយលក្ខណ៍អក្សរដែលចេញដោយចៅក្រមម្នាក់។ ជាក់ស្ដែងនៅក្នុងដីកាហាមឃាត់ គឺជាដីកាបញ្ជារបស់តុលាការមួយដល់មនុស្សណាម្នាក់ឱ្យឈប់ធ្វើអំពើ ឬ ដំណើរប្រព្រឹត្តណាម្យ៉ាងជាបណ្ដោះអាសន្ន។ ម្យ៉ាងវិញទៀត ដីកាក៏ជាបញ្ជាលាយលក្ខណ៍អក្សរដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចដែលបង្គាប់ឱ្យចាត់ការនូវអំពើណាមួយម្យ៉ាង ជាពិសេសបញ្ជាដែលបង្គាប់ឱ្យចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ដែលចេញដោយតុលាការ អង្គការ ឬមន្ត្រីផ្លូវការណាម្នាក់។[80] ដូច្នេះហើយទាក់ទងការចេញដីកានេះក្នុងនាមជាចៅក្រមស៊ើបសួរអាច ចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន[81] ដែលមានអត្ថន័យដូចតទៅ

#### ក. ដីកាបង្គាប់ឱ្យចូលខ្លួន

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន។[82] ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាការបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យចូលខ្លួនអាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ការចេញដីកាបង្គាប់ឱ្យចូលខ្លួននេះផងដែរ ត្រូវជូនដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ តាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលាជាដើម។ ហើយនៅពេលដែលបុគ្គលបានទទួលនូវចុងដីកា ត្រូវធ្វើការចុះហត្ថលេខានៅលើដីកាដើម ដែលនឹងត្រូវធ្វើការបង្វិលទៅចៅក្រមស៊ើបសួរវិញ។ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវធ្វើការជូនដំណឹងដល់ចៅក្រមស៊ើបសួរប្រសិនបើមានការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។[83]

---

[79] តាមការឱ្យនិយមន័យក្នុងវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត

[80] តាមការឱ្យនិយមន័យក្នុងវចនានុក្រមតម្រាច្បាប់។

[81] មាត្រា១៨៥ ,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[82] មាត្រា១៨៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[83] មាត្រា១៨៨,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

នៅក្នុងដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានការចុះនិទ្ទេសដែលចាំបាច់សំខាន់ៗដូចជា អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ នូវឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។[84] ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ ដីកានេះប្រើសម្រាប់ជនជាប់សង្ស័យដែលព្រះរាជអាជ្ញាចាប់ផ្តើមចោទប្រកាន់។ ដីកាបង្គាប់ឱ្យចូលខ្លួនជាការដាក់លក្ខខណ្ឌព្រមានដល់ជនជាប់ចោទ ថាបើមិនចូលខ្លួនតុលាការនឹងចាត់ការប្រើកម្លាំងសាធារណៈបង្ខំឱ្យចូលខ្លួន។ ជួនកាលដីកាបង្គាប់ឱ្យចូលខ្លួនអាចចេញបានម្តងទៀតបើជនសង្ស័យមិនបានចូលខ្លួនតាមការបង្គាប់។

គួរបញ្ជាក់ផងដែរថា ការចេញដីកាបង្គាប់ឱ្យចូលខ្លួននេះ គឺជាការកោះហៅបុគ្គលទាំងឡាយណាដែលមានការពាក់ព័ន្ធនៅក្នុងបទល្មើសដែលបានចោទប្រកាន់ ឬបានប្តឹងមកតែប៉ុណ្ណោះ ដើម្បីធ្វើការផ្តល់ចម្លើយ ឬវត្ថុតាងផ្សេងៗដែលមានប្រយោជន៍ក្នុងដំណើរការនីតិវិធី ដែលចៅក្រមខ្លួនគាត់ចង់ដឹង ឬចង់បានចំពោះបុគ្គលណាម្នាក់ក្នុងការស្វែងរកឱ្យឃើញអំពីពិរុទ្ធភាពរបស់ជនជនត្រូវចោទ។

**ខ. ដីកាបង្គាប់ឱ្យនាំខ្លួន**

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាការបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ហើយដីការបង្គាប់ឱ្យនាំខ្លួននេះ អាចត្រូវបានចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។[85]

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួន។[86] ប្រសិនបើដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានទទួលដោយត្រឹមត្រូវពីសំណាក់ជនជាប់សង្ស័យ ឬជនជាប់ចោទ ហើយបើជននេះនៅតែរឹងទទឹងមិនព្រមចូលមកតុលាការតាមថ្ងៃ និងពេលកំណត់ទេ នោះចៅក្រមស៊ើបសួរអាចចេញដីកាមួយទៀតហៅថា ដីកាបង្គាប់ឱ្យនាំខ្លួន។ ហើយនៅក្នុងដីកាបង្គាប់ឱ្យនាំខ្លួននេះ ត្រូវមានចុះនិទ្ទេសដូចជាអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។[87] ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។ ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ចំពោះដីកាច្បាប់ដើមត្រូវប្រគល់

[84] មាត្រា១៨៧,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[85] មាត្រា១៩០,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[86] មាត្រា១៨៩,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[87] មាត្រា១៩១,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានេះ។

មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង៦(ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨(ដប់ប្រាំបី)ល្ងាចបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ អំពីការលំបាកក្នុងការអនុវត្តបេសសកកម្មរបស់ខ្លួន[88]។ ប្រសិនបើមូលហេតុនៃកាលៈទេសៈបុគ្គលដែលពាក់ព័ន្ធមិនអាចនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំខ្លួន ទៅបង្ហាញខ្លួនយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួស។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវដោះលែងឱ្យមានសេរីភាពវិញ។

**គ. ដីកាបង្គាប់ឱ្យចាប់ខ្លួន**

ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាការបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្វែងរកចាប់ខ្លួន និងនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងការឃុំខ្លួននោះ[89]។ ដីកានេះមានតួនាទី៣សំខាន់ៗ គឺ ស្វែងរក ចាប់ខ្លួន និងឃុំខ្លួន។ នៅពេលដែលដីកាបង្គាប់ឱ្យចាប់ខ្លួនបានចេញ ហើយបុគ្គលដែលស្វែងរកនោះត្រូវបានរកឃើញ និងចាប់ខ្លួនពុំចាំបាច់ចេញដីកាបង្គាប់ឱ្យឃុំខ្លួនទៀតនោះទេ ព្រោះដីកាបង្គាប់ឱ្យចាប់ខ្លួនមានតម្លៃស្មើនឹងការបញ្ជាឱ្យបុគ្គលិកពន្ធនាគារទទួល និងឃុំខ្លួនបុគ្គលដែលពាក់ព័ន្ធ។ ដីកានេះអាចចេញបានតែទៅលើបុគ្គលដែលរត់គេចខ្លួន ឬក្នុងករណីដែលបុគ្គលនោះរស់នៅក្រៅប្រទេសកម្ពុជា ឬរស់នៅកន្លែងដែលមិនស្គាល់ ក្នុងលក្ខខណ្ឌដែលអំពើដែលស្ដីបន្ទោសជាបទឧក្រិដ្ឋ ឬមជ្ឈិមដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។ ចៅក្រមស៊ើបសួរត្រូវសុំយោបល់ពីព្រះរាជអាជ្ញា។ នេះជាមូលហេតុដែលដីកាទាំងនេះអាចត្រូវបានផ្សព្វផ្សាយជាអន្តរជាតិ ដោយមានអន្តរាគមន៍របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បុគ្គលពាក់ព័ន្ធត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន។ ក្នុងករណីពុំអាចធ្វើដូចនេះបាន គាត់ត្រូវសួរចម្លើយដោយព្រះរាជអាជ្ញានៅកន្លែងឃុំខ្លួន។ ព្រះរាជអាជ្ញាត្រូវធ្វើកំណត់ហេតុស្ដាប់ចម្លើយ ដែលត្រូវបញ្ជូនទៅឱ្យចៅក្រមស៊ើបសួរ។

នៅពេលដែលបុគ្គលពាក់ព័ន្ធ ត្រូវជាប់ពន្ធនាគារបន្ទាប់ពីអនុវត្តដីកានេះរយៈពេលនៃការជាប់ពន្ធនាគារត្រូវគិតរួមបញ្ចូលទាំងរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន។ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវមានចុះនិទ្ទេសដូចជាអត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសនេះ ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះ

[88] មាត្រា១៩២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[89] មាត្រា១៩៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង[90]។

**ឃ. ដីកាបង្គាប់ឱ្យឃុំខ្លួន**

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬមជ្ឈមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនចំពោះជនត្រូវចោទ។ ចៅក្រមស៊ើបសួរ នឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួន តែក្នុងករណីដែលជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន[91]។ និទ្ទេសដែលត្រូវចុះមានដូចជា អត្តសញ្ញាណរបស់ជនត្រូវចោទ ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់កំណត់ និងបង្ក្រាបបទល្មើសនេះ ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ហើយដីកាបង្គាប់ឱ្យឃុំខ្លួន ត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា[92]។ តួនាទីចម្បងរបស់ដីកានេះសម្រេចឱ្យមាន ការឃុំខ្លួនបណ្តោះអាសន្ន។ ដូច្នេះអាចសន្មតបានថាបុគ្គលដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ចៅក្រមរួចទៅហើយ ដោយសារគាត់បានបង្ហាញខ្លួនភ្លាមៗ ឬត្រូវបាននាំមកជូនដល់ចៅក្រមស៊ើបសួរដោយព្រះរាជអាជ្ញា (បន្ទាប់ពីការស៊ើបអង្កេតរបស់នគរបាល) ឬតាមដីកាបង្គាប់ឱ្យចូលខ្លួនឬដោយសារគាត់ត្រូវបានឃុំខ្លួនរួចទៅហើយ។

**កថាខណ្ឌទី២៖ ការឃុំខ្លួនបណ្តោះអាសន្ន**

ជាគោលការណ៍ ជនត្រូវចោទគ្រប់រូបត្រូវមានសិទ្ធិសេរីភាព មិនត្រូវបានឃុំខ្លួននោះទេ។[93] តែទោះជាយ៉ាងនេះក្តី ចៅក្រមស៊ើបសួរ អាចសម្រេចឃុំខ្លួនជនត្រូវចោទណាមួយជាបណ្តោះអាសន្នបាន នៅក្នុងអំឡុងពេលនៃនីតិវិធីមុនការជំនុំជម្រះ កាលណាករណីនោះជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវអនុវត្តទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១(មួយ)ឆ្នាំ។ ហើយកាលណា បុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានឃុំខ្លួននោះ ចិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន[94]។ ដែលការឃុំខ្លួនបណ្តោះអាសន្ននេះ ធ្វើឡើងដោយសារមូលហេតុមួយចំនួនព្រមទាំងមានការបញ្ជាក់អំពីចិរវេលានៃការឃុំខ្លួននេះនឹងមានការបកស្រាយជូនដូចតទៅ

**ក. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន**

យោងតាមមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានធ្វើការកំណត់អំពីកាលៈទេសៈពិសេសដែលចៅក្រមស៊ើបសួរអាចអនុញ្ញាតឱ្យមានការឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទបានដោយសារ[95]៖

- ដើម្បីបញ្ចប់បទល្មើសបង្ការទប់ស្កាត់បទល្មើសកុំឱ្យកើតជាថ្មី

[90] មាត្រា១៩៨ ,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[91]មាត្រា២២០, ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[92]មាត្រា២២១,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[93]មាត្រា ២០៣,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[94]មាត្រា១៩៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[95]មាត្រា២០៥,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់មកលើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈរក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

**ខ. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

ចំពោះនីតិជនដែលត្រូវចោទពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៦(ប្រាំមួយ)ខែបានទេ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចធ្វើការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នម្តងបាន៦(ប្រាំមួយ)ខែ ដោយមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នបានតែ២(ពីរ)ដងគត់[96]។ ចំពោះការឃុំខ្លួនបន្ថែមដែលមានរយៈពេល១២(ដប់ពីរ)ខែ មិនមែនជាការឃុំខ្លួនដែលកើតចេញពីដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ននោះទេ។ អនីតិជនអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមានដូចជា

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៤(បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង១៦ (ដប់ប្រាំមួយ)ឆ្នាំ។
- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៦(ប្រាំមួយ)ខែ បានទេ កាលណាអនីតិជននោះមានអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ដល់ក្រោម១៨ (ដប់ប្រាំបី)ឆ្នាំ[97]។

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៤(បួន)ខែ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នបានតែម្តងគត់មិនឱ្យលើសពី២(ពីរ)ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ហើយថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះមិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[98]។ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះមានអានុភាព ក្នុងការឃុំខ្លួនជនណាម្នាក់បានត្រឹមតែរយៈពេល៤(បួន)ខែប៉ុណ្ណោះ។ អនីតិជនអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលាឃុំខ្លួនបណ្តោះអាសន្នដូចជាៈ

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី២(ពីរ)ខែបានទេ កាលណាអនីតិជននេះមានអាយុតិចជាង១៦ (ដប់ប្រាំមួយ)ឆ្នាំ។

[96]មាត្រា២០៨ ,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[97] មាត្រា២១៣ ,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[98] មាត្រា២០៩,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៤(បួន) ខែបានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[99]

**ចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម៖** ក្នុងករណីពិសេសដែលមានការចោទប្រកាន់ ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី១(មួយ)ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នម្តងបាន១(មួយ)ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់[100]។ ម្យ៉ាងវិញទៀត ចំពោះអនីតិជនដែលមានអាយុក្រោម១៤(ដប់បួន)ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នបាននោះទេ ប៉ុន្តែអាចប្រគល់អនីតិជននេះទៅឱ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬប្រគល់ទៅឱ្យមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរងចាំសេចក្តីសម្រេចរបស់តុលាការ។[101]

**កថាខណ្ឌទី៣៖ ដីកាដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ**

កាលណាមានការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបាន អាចធ្វើឡើងដោយតាមការផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរ តាមការសុំរបស់ព្រះរាជអាជ្ញា និងតាមពាក្យសុំរបស់ជនត្រូវចោទ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ

**ក. តាមរយៈចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា។ កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងនេះឱ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥(ប្រាំ)ថ្ងៃបន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាមបានដោយមិនរង់ចាំយោបល់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន[102]។

**ខ. តាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាក៏អាចផ្តើមគំនិតសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនអាចសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ក្នុងករណីនេះចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ។ ហើយចំពោះដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំនេះក៏ត្រូវមានសំអាងហេតុដែរ។[103]

---

[99] មាត្រា២១៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[100] មាត្រា២១០,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[101] មាត្រា២១២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[102] មាត្រា២១៥,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[103] មាត្រា២១៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**គ. តាមបណ្តឹងស្នើសុំរបស់ជនត្រូវចោទ**

ជនត្រូវចោទក៏អាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលាទៅចៅក្រមស៊ើបសួរបាន។ ហើយបន្ទាប់មកចៅក្រមស៊ើបសួរត្រូវ បញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥(ប្រាំ)ថ្ងៃបន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល១(មួយ)ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យនេះក្នុង រយៈពេល៥(ប្រាំ)ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំ។ ដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរ[104]។

**កថាខណ្ឌទី៤៖ ការត្រួតពិនិត្យតាមផ្លូវតុលាការ**

**ក. លក្ខខណ្ឌនៃការត្រួតពិនិត្យ**

ប្រសិនបើចៅក្រមស៊ើបសួរ មានការព្រួយបារម្ភចំពោះទង្វើរបស់ជនត្រូវចោទ និងភ័យខ្លាចថាអាចមានការជ្រៀតជ្រែកប៉ះពាល់ដល់ការស៊ើបសួរ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យដាក់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលនេះជាជម្រើសមួយក្រៅពីការឃុំខ្លួនបណ្តោះអាសន្នមកដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអាចអនុវត្តទៅបានតែក្នុងករណីដែលជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ[105] និងការត្រួតពិនិត្យតាមផ្លូវតុលាការនេះអាចអនុវត្តបានទាំងទៅលើជនត្រូវចោទជានីតិជន និងអនីតិជនដែលមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំឡើងទៅ។[106] ស្របតាមការលើកឡើងនេះ យើងអាចសន្និដ្ឋានបានថា បើកាលណាដែលជនល្មើសដែលបានប្រព្រឹត្តកំហុសត្រឹមតែជាការពិន័យជាប្រាក់សុទ្ធសាធទេ នោះចៅក្រមស៊ើបសួរពុំអាចធ្វើការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះបានឡើយ។ ដូច្នេះទើបតម្រូវឱ្យបទល្មើសដែលកើតនោះត្រូវតែជាបទល្មើសដែលច្បាប់កំណត់ថាផ្តន្ទាទោសដាក់ពន្ធនាគារចំពោះនីតិជន និងអនីតិជនដែលមានអាយុចាប់ពីអាយុ១៤(ដប់បួន)ឆ្នាំឡើងទៅតែប៉ុណ្ណោះ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយឬច្រើនដូចជា មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីដែលកំណត់ដោយចៅក្រមស៊ើបសួរ មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ប្រគល់ជូនដល់ការិយាល័យ

[104]មាត្រា២១៧ ,ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[105]មាត្រា២២៣,ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[106]មាត្រា២២៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ក្រឡាបញ្ជីគ្រប់ឯកសារត្រូវបញ្ជាក់អំពី អត្តសញ្ញាណ មិនត្រូវបើកបររថយន្ត មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់ ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។ ប៉ុន្តែដើម្បីអនុវត្តចំណុចទី១២ខាងលើ ចៅក្រមស៊ើបសួរ មិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោតឬសកម្មភាពខាងសហជីពបានទេ។[107]

ប្រសិនបើជនត្រូវចោទមិនគោរពតាមកាតព្វកិច្ចណាមួយនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទនោះជាបណ្តោះអាសន្ន។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នបាន ទោះបីជាទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមានៃការឃុំខ្លួនក៏ដោយ។[108]

**ខ. មូលហេតុនៃការដាក់ឱ្យត្រួតពិនិត្យ**

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ របស់ចៅក្រមស៊ើបសួរនេះគឺគាត់ធ្វើឡើងដោយសារតែមូលហេតុចំនួន៤យ៉ាងសំខាន់ៗដូចជា ដើម្បីធានាឱ្យជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខតុលាការ បន្ថយសេរីភាពមួយចំនួន កុំឱ្យកើតមាននូវបទល្មើសបន្តទៀត ដាក់កំហិតនូវការព្យាបាលផ្នែកសង្គម ឬផ្នែកវិទ្យាសាស្ត្រ និងដាក់ប្រាក់ធានាដើម្បីទុកសងការខូចខាតដល់ជនរងគ្រោះ។[109]

**កថាខណ្ឌទី៥៖ បុគ្គលដែលអាចកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ**

ជាគោលការណ៍ដែលបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការច្បាប់បានធ្វើការផ្តល់អំណាចដោយឆន្ទានុសិទ្ធិចំពោះចៅក្រមស៊ើបសួរ ដោយព្រះរាជអាជ្ញា និងជនត្រូវចោទ។ ដែលមានអត្ថន័យដូចតទៅ

**ក. ចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា។ ហើយចៅក្រមស៊ើបសួរអាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[110]។

**ខ. បណ្តឹងសុំរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាអាចសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រម

---

[107] មាត្រា២២៣,ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[108] មាត្រា២៣០,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[109] ឧត្តមសេនីយ៍ត្រី អាន សុរីដា,សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន ,បោះពុម្ពលើកទី២ ឆ្នាំ២០២១ ទំព័រ៨៤។

[110] មាត្រា២២៧ ,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។ ហើយដីកាសម្រេចនេះត្រូវធ្វើការជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានធ្វើការសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចដាក់ពាក្យសុំទៅសភាស៊ើបសួរ ដែលត្រូវសម្រេចជំនួសចៅក្រមស៊ើបសួរ។ រាល់ដីកាដែលសម្រេចមិនព្រមធ្វើតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញាត្រូវតែមានសំអាងហេតុ[111]។

**គ. បណ្តឹងសុំរបស់ជនត្រូវចោទ**

ជនត្រូវចោទអាចធ្វើពាក្យបណ្តឹងសុំឱ្យលើកលែង ឬធ្វើការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនេះភ្លាមទៅកាន់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ និងជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ កាលណាមានពាក្យសុំឱ្យលើកលែង ឬឱ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មីមុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេល៥(ប្រាំ)ថ្ងៃនេះ ត្រូវចាប់ផ្តើមគិតពីពេលចេញសេចក្តីសម្រេចលើពាក្យសុំពីមុន។ ដីកាដែលម្រេចមិនព្រមធ្វើតាមពាក្យសុំត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនេះទេ ជនត្រូវចោទ អាចធ្វើពាក្យបណ្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[112]។

**កថាខណ្ឌទី៦៖ ស្ថានភាពគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យរបស់តុលាការ**

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនា ពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ហើយចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទត្រូវឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា២០៨ (ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា២១០(ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍) មាត្រា២១៣(ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹង អនីតិជនមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ និងមាត្រា២១៤ (ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ នៃក្រមនេះក៏ដោយ។ កាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនជនត្រូវចោទ។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទតាមដីកាដែលមានសំអាងហេតុ ហើយត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ដល់ជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ(ប្រសិនបើមាន) ហើយការខុំខ្លួនបណ្តោះអាសន្ននេះមិនអាចឱ្យលើសពី៤(បួន)ខែ ចំពោះនីតិជន និង២(ពីរ)ខែ ចំពោះអនីតិជន។[113]

[111] មាត្រា២២៨,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[112] មាត្រា២២៩,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[113] មាត្រា២៣០,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

# ជំពូកទី៣
# ការបិទបញ្ចប់ការសើបសួរ

# ជំពូកទី៣
# ការបិទបញ្ចប់ការស៊ើបសួរ

## ផ្នែកទី១៖ នីតិវិធីត្រៀមបិទការស៊ើបសួរ

### កថាខណ្ឌទី១៖ ការជូនដំណឹងពីការបិទការស៊ើបសួរ

ចៅក្រមស៊ើបសួរ ពិនិត្យវាយតម្លៃដោយអធិបតេយ្យនូវខណៈពេលដែលត្រូវបញ្ចប់ការស៊ើបសួរជាអាទិ៍នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការរកភស្តុតាងមិនតម្រូវឱ្យមានកិច្ចការស្រាវជ្រាវអ្វីមួយ នោះចៅក្រមស៊ើបសួរគាត់សម្រេចបិទការស៊ើបសួររបស់គាត់បាន។ គួរបញ្ជាក់ថានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះពុំមានចែងអំពីចិរវេលានៃការស៊ើបសួរទេ។ ប៉ុន្តែយើងអាចគិតថាវាជាសមត្ថកិច្ចរបស់សភាស៊ើបសួរក្នុងការធានារ៉ាប់រងឱ្យការស៊ើបសួរនេះ ត្រូវធ្វើឡើងក្នុងចិរវេលាសមរម្យណាមួយដោយពុំទុកឱ្យសំណុំរឿងជួបនឹងរយៈពេលយូរអន្លាយពេកទៅបានហើយ។

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវទុកសំណុំរឿងឱ្យមេធាវីជនជាប់ចោទពិនិត្យ ហើយជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។ បន្ទាប់ ២ថ្ងៃ ក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ដែលហៅថា"**ដីកាបញ្ជូនរឿងទៅពិនិត្យមូល**"។[114] នៅក្នុងដីកាបញ្ជូនរឿងពិនិត្យមូលនេះផងដែរ ចៅក្រមស៊ើបសួរអាចត្រូវភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងពីអង្គហេតុ ចម្លើយដែលបានមកពី ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬតំណាងរបស់ខ្លួន ចម្លើយរបស់សាក្សី ចម្លើយរបស់ជនត្រូវចោទ និងឯកសារ ឬភស្តុតាងផ្សេងទៀតដែលចៅក្រមស៊ើបសួរបានស្រាវជ្រាវកន្លងមក។ ការជូនដំណឹងអំពីការបិទការស៊ើបសួរនេះ ក៏ជាការទុកលទ្ធភាពឱ្យគូភាគីមានឱកាសក្នុងការផ្ដល់ភស្តុតាងបន្ថែមផ្សេងទៀត ឬអាចស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយដែលភាគីគិតថាមានប្រយោជន៍សម្រាប់រឿងក្ដីរបស់ខ្លួន និងម្យ៉ាងទៀតភាគីអាចមានសិទ្ធិក្នុងការប្ដឹងសុំមោឃភាពនូវការស៊ើបសួរនោះបាន។ ដែលនេះជាចំណុចដែលមានសារៈសំខាន់បំផុត និងជាគោលការណ៍គោរពនូវសិទ្ធិ និងផលប្រយោជន៍របស់គូភាគីវិវាទផងដែរ ពីព្រោះនៅពេលណាដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយរួចហើយ ដីកានេះនឹងត្រូវលុបលាងមោឃភាពនៃនីតិវិធីមុន ហើយគ្មានមោឃភាពណាមួយនៃនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការដែលកំពុងជំនុំជម្រះបានទៀតនោះទេ។

នៅអំឡុងពេលនីតិវិធីត្រៀមបិទការស៊ើបសួរនេះក៏បានធ្វើការបញ្ញត្តិថា ក្រៅពីចៅក្រមស៊ើបសួរក្នុងការបិទការស៊ើបសួរក៏ពិតមែន ប៉ុន្តែច្បាប់ក៏បានផ្ដល់សិទ្ធិក្នុងការស្នើសុំឱ្យបិទការស៊ើបសួរនេះបានដែរ ក្រៅពីចៅក្រម

[114] មាត្រា២៤៦, កថាខណ្ឌទី១,២, ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ស៊ើបសួរ ដែលអាចធ្វើឡើងតាមរយៈបណ្តឹងសុំរបស់គូភាគីចំណុច (ក) និងតាមរយៈព្រះរាជអាជ្ញានៅចំណុច(ខ) បានផងដែរដែលមានការបកស្រាយជូននៅក្នុងផ្នែកទី១ជំពូកទី៣នេះដូចតទៅ

**ក. ការបិទការស៊ើបសួរតាមបណ្តឹងសុំរបស់ភាគី**

ការសម្រេចបិទការស៊ើបសួរ ជានិច្ចជាកាលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ប៉ុន្តែថិរវេលានៃការបិទនេះក្រមនីតិវិធីព្រហ្មទណ្ឌពុំមានបញ្ជាក់អំពីពេលវេលានៃការបិទណាមួយច្បាស់លាស់នោះទេ។ ដូចឃ្លាមួយលើកឡើងថា "យុត្តិធម៌ដែលប្រកបដោយភាពយឺតយ៉ាវស្មើនឹងអយុត្តិធម៌" ដែលនេះជាពាក្យស្លោកដែលអ្នកតាក់តែងច្បាប់ និងអ្នកអនុវត្តច្បាប់យកមកពិចារណាទៅលើស្ថានភាពនៅក្នុងសង្គមជាក់ស្តែង។ ដូច្នេះកាលបើរឿងក្តីមួយត្រូវបានអូសបន្លាយពេលវេលាហួសហេតុវាគឺជាផលវិបាកដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីផងដែរ។ ហេតុផលទាំងអស់នេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិនូវបទបទប្បញ្ញត្តិមួយចំនួន ដែលអនុញ្ញាតឱ្យភាគីត្រូវចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដើម្បីបញ្ចៀសនូវសភាពអសកម្មណាមួយក្នុងនីតិវិធីផងដែរ។ ហើយភាគីនៅក្នុងរឿងព្រហ្មទណ្ឌអាចជាជនត្រូវចោទ ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីជាដើម បុគ្គលទាំងនេះគាត់មានសិទ្ធិធ្វើពាក្យស្នើសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរបាន។ កាលណាពេលផុតថិរវេលា១ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឱ្យបិទការស៊ើបសួរ ហើយចំពោះអ្នកដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលផុតថិរវេលា១(មួយ)ឆ្នាំក៏អាចសុំឱ្យបិទការស៊ើបសួរនេះបានដូចគ្នា។ ក្នុងករណីនេះផងដែរចៅក្រមស៊ើបសួរអាចមានពេលក្នុងការសម្រេចលើពាក្យបណ្តឹងសុំរយៈពេល១(មួយ)ខែ គិតចាប់ពីពេលទទួលបានពាក្យសុំនេះ។ ហើយប្រសិនបើចៅក្រមស៊ើបសួរមិនបានធ្វើការសម្រេចតាមរយៈពេលកំណត់នេះទេ អ្នកស្នើសុំអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលជាអ្នកមានសិទ្ធិធ្វើអធិបញ្ជាជំនួសឱ្យចៅក្រមស៊ើបសួរជាអ្នកសម្រេច។ ហើយរាល់ពាក្យស្នើសុំរបស់គូភាគីឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរនេះអាចធ្វើការប្រើប្រាស់តាមមេធាវីបាន។[115]

**ខ. តាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាចំពោះគំហើញរបស់ចៅក្រមស៊ើបសួរ**

ក្រោយពីបានទទួលសំណុំរឿងឱ្យពិនិត្យរបស់ចៅក្រមស៊ើបសួរ ហើយដែលទាញចេញពីការពិនិត្យសំណុំរឿងទាំងមូល ដែលក្រមនីតិវិធីព្រហ្មទណ្ឌថ្មីពុំបានធ្វើការបញ្ជាក់អំពីថិរវេលាក្នុងការពិនិត្យសំណុំរឿងនេះទេ ប៉ុន្តែបើយើងសង្កេតទៅមើលច្បាប់នីតិវិធីព្រហ្មទណ្ឌចាស់ឆ្នាំ១៩៩៣ ត្រង់មាត្រា ៨៩ កថាខណ្ឌទី២ ព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនមួយជាលាយលក្ខណ៍អក្សរនៅក្នុងរះពេល៣ថ្ងៃនេះ ចាប់ពីពេលទទួលបានសំណុំរឿងនេះ រួចធ្វើការបញ្ជូនទៅចៅក្រមស៊ើបសួរទាំងសេចក្តីសន្និដ្ឋានទាំងសំណុំរឿង។ ហើយដីកាសន្និដ្ឋានរបស់

---

[115] រៀបរៀងដោយ ឌី លីឡា និង ខាន់ សុខា, នីតិវិធីព្រហ្មទណ្ឌ ទំព័រទី៧៥។

ព្រះរាជអាជ្ញាពុំមានសិទ្ធិអំណាចបង្ខំឱ្យចៅក្រមស៊ើបសួរយល់ស្របតាមនោះទេ។

ក្រោយពេលព្រះរាជអាជ្ញាទទួលបានសំណុំរឿងពីចៅក្រមស៊ើបសួរ ហើយព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងនេះមិនទាន់ចប់សព្វគ្រប់ទេនោះ ព្រះរាជាអាជ្ញានឹងផ្ញើសំណុំរឿងនេះទៅចៅក្រមស៊ើបសួរ ដើម្បីធ្វើការស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរបន្ថែម តាមដីកាចាត់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា ចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មី ឬបន្ថែមនេះទៀត នោះព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២(ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា)បាន។

ព្រះរាជអាជ្ញា ក្រោយពីបានទទួលសំណុំរឿងតាមដីកាបញ្ជូនរឿងឱ្យពិនិត្យមូលរបស់ចៅក្រមស៊ើបសួរ ត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរមុន ទើបចៅក្រមស៊ើបសួរធ្វើដីកាសម្រេចតាមក្រោយ(ដូចជា ដីកាសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ជាដើម) ទោះបីចៅក្រមស៊ើបសួរយល់ស្រប ឬមិនយល់ស្របនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាក៏ដោយ។ ច្បាប់បានធ្វើការបើកឱ្យចៅក្រមស៊ើបសួរធ្វើការសម្រេចប្រកបដោយអធិបតេយ្យ គឺមិនអាចទទួលឥទ្ធិពលពីបុគ្គលណាផ្សេងទៀតបានឡើយ។ កាលណាបើចៅក្រមស៊ើបសួរធ្វើការសម្រេចហើយ ព្រះរាជអាជ្ញាមិនអាចធ្វើការបង្ខំឱ្យចៅក្រមស៊ើបសួរឱ្យសម្រេចតាមដីកាសន្និដ្ឋានរបស់ខ្លួនបានទេ មានតែផ្លូវមួយប៉ុណ្ណោះដែលបើកឱ្យព្រះរាជអាជ្ញាជំទាស់បាន គឺតាមរយៈការប្តឹងឧទ្ធរណ៍។ ម្យ៉ាងវិញទៀតក្នុងករណីដែលជនត្រូវចោទនោះបានស្លាប់ ក្រោយពីចៅក្រមស៊ើបសួរបានស៊ើបសសួរចប់សព្វគ្រប់ហើយ ព្រះរាជអាជ្ញាអាចធ្វើការចារលើសេចក្តីសន្និដ្ឋានអំពីការរលត់បណ្តឹងអាជ្ញាបាន ប៉ុន្តែត្រូវរំលឹកដល់ចៅក្រមស៊ើបសួរអំពីការខូចខាតខាងសំណងរដ្ឋប្បវេណីដែលបង្កឡើងដោយអំពើរបស់ជនត្រូវចោទ។ ដូច្នេះចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទាំងមូលនេះ ទៅកាន់តុលាការរដ្ឋប្បវេណីដើម្បីជំនុំជម្រះអំពីបញ្ហាខាងសំណងរដ្ឋប្បវេណីតែម្តង។[116]

ក្រោយពីពិនិត្យសំណុំរឿងដែលចៅក្រមស៊ើបសួរបានបញ្ជូនមកចប់សព្វគ្រប់ ព្រះរាជាអាជ្ញាមានតួនាទីត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចំពោះការពិនិត្យមើលសំណុំរឿងរបស់ជនត្រូវចោទនៅក្នុងឃុំគឺមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ និងមានរយៈពេល១(មួយ)ខែ សម្រាប់ជនត្រូវចោទនៅក្រៅឃុំ។ ហើយចំពោះដែលចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។[117]

ក្នុងករណីដែលចៅក្រមស៊ើបសួរមិនព្រមធ្វើតាមដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងចិរវេលារយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបាន។ ហើយដីកាសម្រេចរបស់

[116] កុយ នាម, ដំណើរការក្តីនៅក្នុងតុលាការកម្ពុជា,បោះពុម្ពលើកទី១,ភ្នំពេញ មីនា ឆ្នាំ១៩៩៨,ទំព័រ១៦៦ដល់ទំព័រ១៦៨។

[117] មាត្រា២៤៦,កថាខណ្ឌទី៤,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងបន្ទាន់ទៅកាន់ព្រះរាជអាជ្ញា។ ប៉ុន្តែក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានធ្វើការឆ្លើយតប ឬសម្រេចក្នុងចិរវេលា១៥(ដប់ប្រាំ)ថ្ងៃនេះទេ ព្រះរាជអាជ្ញាមានសិទ្ធិប្តឹងទៅសភាស៊ើបសួរជាអ្នកសម្រេចជំនួសបាន។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូច ចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់[118]។

## ផ្នែកទី២៖ ការបិទការស៊ើបសួរដោយចៅក្រមស៊ើបសួរ

ជាគោលការណ៍ ការបិទការស៊ើបសួរ គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរក្នុងការចេញដីកាដំណោះស្រាយមួយប្រកបដោយភាពពិតជាក់ស្តែង និងយុត្តិធម៌ចំពោះគូភាគី។ ដែលនៅដំណាក់កាលចុងក្រោយ ប្រសិនបើព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរនេះផ្ទាល់បានយល់ស្របគ្នាក្នុងការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ នោះចៅក្រមស៊ើបសួរត្រូវធ្វើដីកាបញ្ជូនជនត្រូវចោទ និងសំណុំរឿង ព្រមទាំងភស្តុតាងនានាទៅតុលាការជំនុំជម្រះ ដែលហៅថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ របាយការណ៍ព្រមទាំង សំណុំរឿងទាំងអស់ត្រូវដាក់ជូនទៅប្រធានតុលាការដើម្បីចាត់ការតាមច្បាប់។ ប្រសិនបើតុលាការយល់ឃើញថាសំណុំរឿងមូលចប់សព្វគ្រប់ហើយ បន្ទាប់មកប្រធានតុលាការនោះ នឹងចាត់តាំងចៅក្រមជំនុំជម្រះម្នាក់ដោយគិតគូរពីវិសមិតភាពចៅក្រមជាមុនផងដែរ។ ចៅក្រមដែលបានចាត់តាំងកំណត់ថ្ងៃជំនុំជម្រះដោយខ្លួនឯង តាមធម្មតា២០ថ្ងៃក្រោយពីការទទួលសំណុំរឿង ដើម្បីឱ្យភាគីទាំងអស់មានពេលគ្រប់គ្រាន់ដើម្បីរៀបចំសំណុំរឿង។ ចៅក្រមជំនុំជម្រះអាចជាចៅក្រមណាក៏បាន ក្រៅពីចៅក្រមស៊ើបសួរលើរឿងហេតុនោះ ឬក៏អាចជាប្រធានតុលាការតែម្តងក៏បានដើម្បីទទួលបន្ទុកធ្វើការជំនុំជម្រះលើរឿងក្តីនោះ។[119]

### កថាខណ្ឌទី១៖ ប្រភេទដីកាដំណោះស្រាយ

គ្រប់ដីកាទាំងអស់របស់ចៅក្រមស៊ើបសួរដីកាដំណោះស្រាយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចុះកាលបរិច្ឆេទ និងហត្ថលេខារបស់ចៅក្រម និងក្រឡាបញ្ជី។ ហើយក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឱ្យដីកាទាំងនេះចែងនូវធាតុផ្សេងៗដែលអនុញ្ញាតឱ្យកំណត់អត្តសញ្ញាណជនត្រូវចោទដូចជា គោត្តនាម ទីកន្លែង និងថ្ងៃខែឆ្នាំកំណើត លំនៅឋាន និងមុខងាររបស់បុគ្គលនេះ។ ប្រសិនបើមិនមានកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ក្នុងដីកាទេ ដីកានឹងទុកជាមោឃៈ។

---

[118] មាត្រា ២៤៦,កថាខណ្ឌទី៥,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[119] កុយ នាម, ដំណើរការក្តីនៅក្នុងតុលាការកម្ពុជា,បោះពុម្ពលើកទី១,ភ្នំពេញ មីនា ឆ្នាំ១៩៩៨,ទំព័រ១៧១។

ដីកាបង្ហាញឈ្មោះបទល្មើសដែលច្បាប់បានកំណត់ និងដែលដាក់បន្ទុកទៅលើជនត្រូវចោទ ព្រមជាមួយនឹងមូលហេតុដែលមាន ឬគ្មានបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងបុគ្គលនោះ។ ដីកាធ្វើឱ្យមានការប្រគល់សងឯកសារអត្តសញ្ញាណដែលបានសុំ ក្នុងពេលស៊ើបសួរ និងអាវុធដែលបានចាប់យក ក្នុងលក្ខខណ្ឌដែលអាវុធនោះមិនបានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស និងប្រាក់ធានាដែលជនត្រូវចោទត្រូវបានបង្ខំឱ្យបង់[120]។ ដីកាដំណោះស្រាយនឹងត្រូវជូនដំណឹងក្នុងចិរវេលាខ្លីបំផុតដល់ព្រះរាជអាជ្ញា,ជនត្រូវចោទ,និងដើមបណ្តឹងរដ្ឋប្បវេណី។

ដីកាដំណោះស្រាយស្ថាពរ មានអានុភាពលុបបំបាត់ចោលពីសំណុំរឿងនូវគ្រប់មោឃភាពទាំងអស់ដែលអាចកើតមានចំពោះសំណុំរឿងនេះ។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅមុខតុលាការជំនុំជម្រះបានទៀតទេ។ ដីកាដំណោះស្រាយស្ថាពរលុបលាងមោឃភាពនៃនីតិវិធីមុនប្រសិនបើមាន[121]។

**គ. ដីកាបញ្ជូនទៅជំនុំជម្រះ**

នៅពេលដែលចៅក្រមស៊ើបសួរ យល់ឃើញថាមានបន្ទុកគ្រប់គ្រាន់អំពើ គឺជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះ។ ដីកានេះត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។[122] ហើយប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការដើម្បីធ្វើការកំណត់ពេលវេលាសវនាការជំនុំជម្រះ។[123] ដីកាបញ្ជូនទៅជំនុំជម្រះដកសមត្ថកិច្ចចៅក្រមស៊ើបសួរទៅឱ្យតុលាការ ដែលសំណុំរឿងបានបញ្ជូនទៅដោយពុំមានចិរវេលាដើម្បីបើកសវនាការ។ ដីកានេះបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែចៅក្រមស៊ើបសួរ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ និងក្រោមលក្ខខណ្ឌមួយចំនួនអាចសម្រេចរក្សាជនត្រូវចោទ ឱ្យនៅជាប់ឃុំរហូតដល់ពេលចូលមកបង្ហាញខ្លួននៅមុខតុលាការរហូតដល់ចប់នីតិវិធីជំនុំជម្រះនេះបាន។

ក្នុងករណីនេះគាត់ត្រូវមានសំអាងហេតុទៅលើសេចក្តីសម្រេចរក្សាឱ្យនៅក្រៅឃុំ ដោយមូលហេតុណាមួយ ក្នុងចំណោមមូលហេតុនានា ដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីបញ្ចប់បទល្មើស ឬដើម្បីបង្ការទប់ស្កាត់បទល្មើសកុំឱ្យកើតជាថ្មី ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។ ប៉ុន្តែជនត្រូវចោទនឹងត្រូវដោះលែងភ្លាមៗ បើសិនគាត់មិន

[120] មាត្រា២៤៧,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[121] មាត្រា២៥៦,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[122] មាត្រា ២៤៧,ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧,នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៦១៣/០០៩,ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។

[123] មាត្រា២៥០,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

បានចូលបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល៤(បួន)ខែ គិតពីកាលបរិច្ឆេទនៃដីកាបញ្ជូនទៅជំនុំជម្រះ។ កាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ អាចត្រូវរក្សាទុកតាមបែបបទតែមួយនឹងការឃុំខ្លួនរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ ផ្ទុយទៅវិញបើរឿងក្តីដែលគាត់ស៊ើបនោះមិនបង្កើតឱ្យមានជាបទល្មើសព្រហ្មទណ្ឌទេ គាត់ត្រូវបិទការស៊ើបសួរតាមរយៈដីកាលើកលែងការចោទប្រកាន់ដែលមានខ្លឹមសារដូចតទៅ

**ខ. ដីកាលើកលែងការចោទប្រកាន់**

ចំពោះដីកាលើកលែងការចោទប្រកាន់នេះចៅក្រមស៊ើបសួរ អាចសម្រេចបិទការស៊ើបសួរបានចំពោះជនត្រូវចោទណាមួយ និងមិនធ្វើការបញ្ជូនគាត់បន្តទៅចំពោះមុខតុលាការវិនិច្ឆ័យបាននៅពេលដែលកើតមានករណីដូចជា អំពើមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ជនដែលប្រព្រឹត្តនៅតែគេមិនស្គាល់ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។[124]ម្យ៉ាងវិញទៀតក្នុងករណីដែលបណ្តឹងអាជ្ញាលត់ ដែលបញ្ជាក់ថាជនត្រូវចោទមិនមានពិរុទ្ធភាពនោះទេ ចៅក្រមស៊ើបសួរសម្រេចចេញដីកាលើកលែងការចោទប្រកាន់បាន។[125] ការសម្រេចចេញដីកាលើកលែងការចោទប្រកាន់នេះ ត្រូវមានចែងនូវមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងទៅដល់ភាគីទាំងអស់ ដើម្បីអាចឱ្យភាគី ដែលមិនមានការសុខចិត្តទៅនឹងដីកាសម្រេចលើកលែងការចោទប្រកាន់នេះ ហើយអាចធ្វើការប្តឹងតវ៉ា ឬដាក់ពាក្យបណ្តឹងទៅឧទ្ធរណ៍បានផងដែរ។ ចំពោះការរលត់បណ្តឹងអាជ្ញា ផុតអាជ្ញាយុកាល ឬក៏មរណភាពនៃចារីចៅក្រមស៊ើបសួរក៏អាចធ្វើការចេញដីកាលើកលែងការចោទប្រកាន់បាន។

ការលើកលែងការចោទប្រកាន់ដោយសារមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរ អាចប្តឹងទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថាបានពាក់ព័ន្ធនឹងបទល្មើស។ ករណីនេះ តុលាកាព្រហ្មទណ្ឌត្រូវសម្រេចរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធផ្សេងទៀតបើមាន។ សាលក្រមស្តីពីការរឹបអូសនេះត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការចេញសាលក្រម និងមានការផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍។ ហើយបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬបានធ្វើការអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងទៅឧទ្ធរណ៍ដើម្បីប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល១(មួយ)ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងរយៈពេល២(ពីរ)ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារ

[124] មាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[125] មាត្រា ២៤៧,ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧,នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៦១៣/០០៩,ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។

ព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ប្រសិនបុគ្គលនេះមិនបានចូលរួមនៅអំឡុងពេលធ្វើការជំនុំជម្រះតាមនីតិវិធីរបស់តុលាការ។

ការលើកលែងការចោទប្រកាន់នេះ អាចលើកលែងទាំងស្រុង ឬមួយផ្នែកបានដែរ មានន័យថាទាក់ទងនឹងអំពើទាំងអស់ដែលដាក់ឱ្យពិនិត្យទៅលើបុគ្គល ឬទាក់ទងត្រឹមតែមួយផ្នែកនៃអំពើនេះ។ ដីកាដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរពីសំណុំរឿងនិងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការនិងការឃុំខ្លួនបណ្តោះអាសន្ន។

ករណីមានការដោះលែងឱ្យមានសេរីភាព នឹងមានការបញ្ជាក់ជាក់លាក់ លុះត្រាតែផុតចិរវេលាប្តឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងភ្លាមៗ។ ប្រសិនបើព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ពី ដីកាលើកលែងការចោទប្រកាន់ ជនត្រូវចោទដែលជាប់ឃុំ ត្រូវរក្សាទុកក្នុងពន្ធនាគារបន្តរហូតដល់ពេលដែលសភាស៊ើបសួរសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ។ ប្រសិនបើសភាស៊ើបសួរយល់ស្របនឹងដីកា ជនត្រូវចោទនឹងត្រូវដោះលែងឱ្យមានសេរីភាព ផ្ទុយទៅវិញបើសភាស៊ើបសួរចេញដីកាបញ្ជូនទៅជំនុំជម្រះ សភាស៊ើបសួរត្រូវសម្រេចអំពីការរក្សាក្នុងឃុំ។ ប៉ុន្តែបើសភាស៊ើបសួរទទួលបន្ទុកការស៊ើបសួរ និងដឹងនាំនីតិវិធីដោយខ្លួនឯងផ្ទាល់ ដីកាលើកលែងការចោទប្រកាន់ចេញដោយសភាស៊ើបសួរ មានអានុភាពដោះលែងជនត្រូវចោទដែលជាប់ឃុំភ្លាម[126]។ ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ពីដីកាលើកលែងការចោទប្រកាន់[127]។ ហើយព្រះរាជអាជ្ញាក៏ដូចជាអគ្គព្រះរាជអាជ្ញាមានអំណាចធ្វើបណ្តឹងឧទ្ធរណ៍ពីគ្រប់ដីការបស់ចៅក្រមស៊ើបសួរ។

សេចក្តីសម្រេចលើកលែងការចោទប្រកាន់ មិនអាចធ្វើឱ្យមានការនូវរលត់បណ្តឹងអាជ្ញាទេ ព្រោះប្រសិនបើការលើកលែងការចោទប្រកាន់មានហេតុផលមកពីអវត្តមាននៃបន្ទុកមិនគ្រប់គ្រាន់ ដែលប្រឆាំងនឹងជនត្រូវចោទ ឬមកពីការពុំស្គាល់ចារីមានបន្ទុកថ្មីអនុញ្ញាតឱ្យបើកការស៊ើបសួរទៅលើអង្គហេតុតែមួយជាថ្មីម្តងទៀតបាន។

**កថាខណ្ឌទី៣៖ បើកការស៊ើបសួរលើបន្ទុកថ្មី**

ករណីមានការបើកការស៊ើបសួរលើបន្ទុកថ្មីនេះកើតឡើងគឺ នៅក្រោយពេលដែលដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងការចោទប្រកាន់របស់សភាស៊ើបសួរបានចូលស្ថាពរ ប្រសិនមានលេចឡើងបន្ទុកថ្មី ការបើការស៊ើបសួរអាចបើកឡើងវិញតាមការស្នើសុំ ឬតាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា។[128] កាលដែលអាចបើកស៊ើបសួរលើបន្ទុកថ្មីនេះបាន លុះត្រាតែដីកាលើលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរមិនទាន់បានផុតរលត់នូវបណ្តឹងអាជ្ញាទេ មានន័យថាប្រសិនបើ ដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ បណ្តាលឱ្យមានការរលត់នូវបណ្តឹងអាជ្ញាដោយសារតែមូលហេតុដូចជា មរណភាពនៃជន

[126] មាត្រា២៨២,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[127] មាត្រា២៦៨,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
[128] មាត្រា ២៥១ និង២៦៥,ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ឬក៏អាជ្ញាអស់ជំនុំជាដើម។

ដូច្នេះក្នុងករណីដែលមានការរកឃើញនូវភស្តុតាងថ្មីក៏ដោយអំពីបទល្មើស ដែលបានបង្ហាញឱ្យឃើញនូវជនល្មើសដែលបានប្រព្រឹត្តបទល្មើសនោះក៏ដោយ ប្រសិនបើអង្គច្បាប់បានផុតរលត់ហើយ នោះអង្គហេតុក៏មិនអាចធ្វើការបើកឱ្យមានការស៊ើបសួរជាថ្មីទៀតបានឡើយ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីឆ្លងកាត់ការបង្ហាញជូន និងបកស្រាយដូចខាងលើយើងខ្ញុំទាំងពីរនាក់បានធ្វើសិក្សាស្រាវជ្រាវយ៉ាងលម្អិតទៅលើប្រធានបទស្តីពី"ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង" អំពីការបើកការស៊ើបសួរ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ អំណាចក្នុងការចេញលើវិធានការនិរន្តរាយ និងនីតិវិធីបិទការស៊ើបសួររួចមក យើងខ្ញុំទាំងពីរអាចទាញបានថា នៅសាលាដំបូងរាជធានីខេត្តនីមួយៗដាច់ខាតគឺត្រូវតែមានមន្ទីរស៊ើបសួរមួយ ដែលមានការចូលរួមពីចៅក្រមស៊ើបសួរ ដែលគាត់ដើរតួនាទីយ៉ាងសំខាន់ក្នុងការបើកការស៊ើបសួរលើអង្គហេតុណាមួយដែលទទួលបានតាមដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់ព្រះរាជអាជ្ញា។ ដែលចៅក្រមស៊ើបសួរគាត់គឺជាអ្នកដើរតួនាទីដឹកនាំដោយផ្ទាល់ដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធក្នុងរឿងក្តី ដើម្បីធ្វើការឆ្លុះបញ្ចាំងឱ្យឃើញនូវការពិតរឿងហេតុចាប់ពីពេលដែលទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ដែលព្រះរាជអាជ្ញាបានចោទប្រកាន់ពីបទល្មើសណាមួយ គិតតាំងពីពេលចាប់ផ្តើមរហូតដល់បញ្ចប់នីតិវិធី។ ចំពោះលក្ខណៈនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ រក្សាការសម្ងាត់ ចំពោះបទឧក្រិដ្ឋការស៊ើបសួរត្រូវតែធ្វើឡើងជាដាច់ខាត ចំណែកបទបទមជ្ឈិមវិញចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរក៏បានមិនស៊ើបសួរក៏បានដែរ។ ចៅក្រមស៊ើបសួរមានតួនាទីស៊ើបសួរស្វែងរកនូវការពិតនៃអង្គហេតុ ហើយស្វែងរកឱ្យឃើញនូវពិរុទ្ធភាពរបស់ជនត្រូវចោទ ការស៊ើបសួររបស់គាត់ក្រោមរូបភាពពីយ៉ាងបន្ថែមទៀត គឺការស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុកដើម្បីជាការផ្តល់ភាពយុត្តិធម៌ មានតម្លាភាព ធានាបានសមភាពទាំងជនត្រូវចោទ និងជនរងគ្រោះ។ ម្យ៉ាងវិញទៀតអំណាចរបស់ចៅក្រមស៊ើបសួរមានទាំង ការស្រាវជ្រាវលើបុគ្គលិកលក្ខណៈរបស់បុគ្គលផងនិងស្រាវជ្រាវទៅលើវត្ថុតាងផងដែរ។

នៅដំណាក់កាលចៅក្រមស៊ើបសួរ ត្រូវមានការបើកការស៊ើបសួរ ដើម្បីធានានូវសុក្រឹតភាពដែលស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិ មានខ្លឹមសារថា ចៅក្រមស៊ើបសួរមិនអាចជាចៅក្រមជំនុំជម្រះបានទេ។ លើសពីនេះទៅទៀតការបើកការស៊ើបសួររបស់គាត់មិនត្រូវធ្វើឡើងតាមទំនើងចិត្តបានទេ គឺកើតឡើងដោយមានការទទួលពាក្យបណ្តឹងជាមុនសិនដោយមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាព្រមទាំងមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ បន្ទាប់ពីនីតិវិធីបើកការស៊ើបសួរហើយទាក់ទងនឹងវិធានការស្រាវជ្រាវដែលជាផ្នែកដ៏សំខាន់សម្រាប់ដំណើរការស៊ើបសួរនេះកាន់តែមានភាពយុត្តិធម៌ ប្រកបដោយតម្លាភាព ក្នុងនោះត្រូវគោរពតាមវិធានការរួមមាន ត្រូវមានការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការចុះទៅកន្លែងកើតហេតុ ការស្តាប់ចម្លើយសាក្សី ការឆែកឆេរនិងការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ ការស្តាប់ទូរស័ព្ទ និងការថតការសន្ទនាជាដើម។ ហើយរាល់នីតិវិធីនេះព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញាក៏អាចមានការចូលរួមបានដែរ។

ក្រៅពីវិធានការស្រាវជ្រាវចៅក្រមស៊ើបសួរក៏នៅមានអំណាចក្នុងដាក់ឱ្យជនត្រូវចោទនូវវិធាននិរន្តរាយមួយចំនួនដែលចៅក្រមស៊ើបសួរតែងតែប្រើប្រាស់ក្នុងការអនុវត្តបេសកកម្មរបស់ខ្លួនរួមមាន ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន។ ដំណាក់កាលចុងក្រោយនៃការស៊ើបសួរបានបញ្ចប់សព្វគ្រប់ហើយ គឺត្រូវបិទការស៊ើបសួរ តាមរយៈដីកាដំណោះស្រាយចំនួនពីរប្រភេទរួមមាន ដីកាបញ្ជូនទៅជំនុំជម្រះ និងដីកាលើកលែងការចោទប្រកាន់។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវរៀបចំរបាយការណ៍មួយហៅថា "**របាយការណ៍ជូនរឿងទៅជំនុំជម្រះ**" កាលបើក្នុងដីកានោះត្រូវបញ្ជូនទៅជំនុំជម្រះមិនថាតែមួយផ្នែក ឬទាំងអស់នោះទេ។ ចំពោះការលើកលែងការចោទប្រកាន់ក៏ដោយមិនថាមួយតែមួយផ្នែក ឬទាំងអស់ត្រូវមានសំអាងហេតុដែរ។ ក្រោយបានរបាយការណ៍ព្រមទាំងសំណុំរឿងទាំងអស់ត្រូវដាក់ជូនទៅប្រធានតុលាការដើម្បីចាត់ការតាមច្បាប់។ ប្រសិនបើតុលាការយល់ឃើញថា សំណុំរឿងមូលសព្វគ្រប់ហើយប្រធាននោះនឹងចាត់តាំងចៅក្រមម្នាក់ទទួលបន្ទុកធ្វើការជំនុំជម្រះលើរឿងក្តីនោះ។

សរុបជារួមមក ដើម្បីធានានូវភាពយុត្តិធម៌ ចៅក្រមស៊ើបសួរពិតជាមានតួនាទីយ៉ាងសំខាន់ណាស់សម្រាប់នៅគ្រប់មន្ទីរស៊ើបសួរ ក្នុងរឿងក្តីព្រហ្មទណ្ឌនេះហើយក៏ជាការលើស្ទួយប្រព័ន្ធតុលាការនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពដែលគួរជាទីទុកចិត្តរបស់ប្រជាពលរដ្ឋគ្រប់រូប។ ដូច្នេះហើយការគោរពសិទ្ធិមនុស្សនេះជាផ្នែកចម្បងមួយដែលពិភពលោកយើងបានកំពុងយកចិត្តទុកដាក់បំផុត ទៅលើសិទ្ធិសេរីភាពរបស់បុគ្គលកាលណាមានភាពយុត្តិធម៌សម្រាប់បុគ្គលគ្រប់រូបនោះទើបច្បាប់យើងមានប្រសិទ្ធភាពទៅបាន។

# អនុសាសន៍

ឆ្លងកាត់ទៅលើការស្រាវជ្រាវលើប្រធានបទ ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង រួចមក យើងខ្ញុំទាំងពីរនាក់ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ យល់ឃើញថាក្នុងដំណាក់កាលស៊ើបសួរដែលអនុវត្តដោយចៅក្រមស៊ើបសួរ ដើម្បីធានាក្នុងការស្វែងរកការពិត ក៏ដូចជាធានាដល់ការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌឱ្យមានប្រសិទ្ធិភាព តម្លាភាព សមភាព សុក្រឹតភាព ដើម្បីស្វែងរកយុត្តិធម៌ពិតប្រាកដជូនជនល្មើស និងជនរងគ្រោះ។ ជាក់ស្តែងដើម្បីធានាបាននូវការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌប្រកដដោយភាពត្រឹមត្រូវ មានការជឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋគ្រប់រូប និងទទួលបានយុត្តិធម៌ពិតប្រាកដ នៅក្នុងដំណាក់កាលស៊ើបសួរ គឺចាំបាច់ណាស់ត្រូវរៀបចំឱ្យមានមន្ទីរស៊ើបសួរមួយច្បាស់លាស់ ដែលត្រូវបំពេញតែកិច្ចស៊ើបសួរ តាមការទទួលបានបណ្តឹងពីសំណាក់អយ្យការ ឬបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាសមត្ថកិច្ចដាច់ដោយឡែករបស់ចៅក្រមស៊ើបសួរ។ កាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរមានសារៈសំខាន់ និងចាំបាច់ដែលមិនអាចខ្វះបាន។ ជាពិសេសចៅក្រមស៊ើបសួរត្រូវមានការផ្តល់កិច្ចសហការចូលរួមពីគ្រប់ស្ថាប័នដែលពាក់ព័ន្ធដែលមានលក្ខណៈសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាការផ្តល់នូវកម្លាំង និងមន្ត្រីដែលមានជំនាញតាមតម្រូវការរបស់ចៅក្រមដែលមានភារកិច្ចទទួលបន្ទុកលើកិច្ចស៊ើបសួរ ហើយចៅក្រមស៊ើបសួរក៏ពុំអាចប្រើប្រាស់អំណាចរបស់ខ្លួនដោយមិនមានការចូលរួមសហការពីស្ថាប័ន និងបុគ្គលដែលពាក់ព័ន្ធផ្សេងៗបានឡើយ។ ហើយដើម្បីឱ្យការស៊ើបសួរមានភាពរឹងមាំ ស្វែងរកការពិត និងផ្តល់ភាពយុត្តិធម៌បាន ចៅក្រមស៊ើបសួរត្រូវចៀសវាងឱ្យបាននូវអគតិទាំង៤ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិឱ្យបានថា ការវិនិច្ឆ័យសម្រេចបាននូវភាពត្រឹមត្រូវប្រកដដោយយុត្តិធម៌ និងសុចរិត ដើម្បីធានាបានថា តុលាការមាននូវប្រព័ន្ធស៊ើបសួរមួយដ៏ត្រឹមត្រូវ និងច្បាស់លាស់ ដែលអាចឱ្យប្រជាពលរដ្ឋជាក់ទុកចិត្តលើប្រព័ន្ធតុលាការបាន។ ដូច្នេះនៅពេលដែលការស៊ើបសួរដែលអនុវត្តដោយចៅក្រមស៊ើបសួរ មានភាពត្រឹមត្រូវ និងស្វែងរកបាននូវយុត្តិធម៌ពិតប្រាកដសម្រាប់ភាគីដែលមកពឹងលើប្រព័ន្ធតុលាការដើម្បីរកយុត្តិធម៌ជូនខ្លួន ដែលត្រូវរងគ្រោះដោយការរំលោភបំពានផ្សេងៗដែលបង្កឡើងដោយជនល្មើស។

ម្យ៉ាងវិញទៀតដើម្បីធានាឱ្យមានភាពលឿនរហ័សនៃនីតិវិធី ព្រោះយើងដឹងហើយថា កាលណាមានរឿងក្តីមួយត្រូវបានធ្វើការចំណាយពេលវេលាយូរហួសហេតុក្នុងការស្វែងរកយុត្តិធម៌នេះ គឺជាការបញ្ជាក់ឱ្យឃើញថាការរកបាននូវភាពយុត្តិធម៌ដែលមានភាពយឺតយ៉ាវ គឺស្មើនឹងភាពអយុត្តិធម៌ទៅវិញនោះទេ។ ដើម្បីធ្វើយ៉ាងណាឱ្យតុលាការនៅកម្ពុជាមាននូវប្រព័ន្ធស៊ើបសួរ ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ធ្វើឡើងដោយមានភាពត្រឹមត្រូវ និងស្តង់ដា ដើម្បីឱ្យប្រជាពលរដ្ឋមានការជឿទុកចិត្តទៅលើប្រព័ន្ធតុលាការកម្ពុជា ដើម្បីស្វែងរកយុត្តិធម៌

ជូនពួកគាត់នៅពេលដែលទទួលរងនូវការរំលោភបំពានផ្សេងៗដែលកើតឡើងនៅក្នុងសង្គមបច្ចុប្បន្ននេះផងដែរ។

ជាចុងក្រោយយើងខ្ញុំទាំងពីរចង់ឱ្យឃើញមានប្រព័ន្ធយុត្តិធម៌ ផ្នែកស៊ើបសួរនេះនៅកម្ពុជាមាននូវគុណភាព ប្រសិទ្ធភាព ដែលតម្រូវឱ្យមន្ត្រីដែលអនុវត្តច្បាប់គ្រប់រូបមានការយកចិត្តទុកដាក់អនុវត្តនីតិវិធីឱ្យបានត្រឹមត្រូវ ហើយចូលរួមផ្សព្វផ្សាយប្រព័ន្ធច្បាប់កម្ពុជាឱ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន ដែលនេះក៏ជាការរួម ចំណែកជួយឱ្យប្រជាពលរដ្ឋទូទៅបានដឹងខ្លះៗអំពីច្បាប់ដែរ ថាអំពើណាដែលគាត់គួរប្រព្រឹត្ត អំពើណាមិនគួរ ប្រព្រឹត្ត ដែលកាត់បន្ថយឱ្យមានការកើតឡើងជាបទល្មើស និងរស់នៅក្នុងសង្គមដោយភាពសុខដុមរមនា ព្រម ទាំងដើម្បីជាសេចក្តីទុកចិត្តរបស់ប្រជាពលរដ្ឋគ្រប់រូបមកលើប្រព័ន្ធនៃការស៊ើបសួរ ឬតុលាការកម្ពុជាពិតជា ប្រកបដោយបរិយាបន្ន។

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
- ច្បាប់ ស្ដីពី ការរៀបចំអង្គការតុលាការ ,លេខ នស/រកម/០៧១៤/០១៥,ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។
- ច្បាប់ស្ដីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។
- ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧,នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៦១៣/០០៩,ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

## ២. សៀវភៅមេរៀនច្បាប់

- សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀង ដោយលោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធិ និង លោកស្រី ចាំង ស៊ីណាត ឆ្នាំសិក្សា ២០១៣- ២០១៤។
- សៀវភៅមេរៀនដំណើរការរឿងក្ដីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន រៀបរៀងដោយ ឧត្តមសេនីយ៍ត្រី អាន សូរីដា បោះពុម្ពលើកទី២ ឆ្នាំ២០២១។
- សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡា និង លោក ខាន់ សុខា

## ៣. ឯកសារផ្សេងទៀតទាក់ទងនិងច្បាប់

- ឯកសារស្រាវជ្រាវ ស្ដីពី តួនាទី និង ភារកិច្ចរបស់ចៅក្រមស៊ើបសួរ ដែលរៀបរៀងដោយ ស៊ន បញ្ញា និង នាំមកជូនដោយគេហទំព័រ វីថី ច្បាប់ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០
- ការស៊ើបសួរដែលរៀបរៀងដោយ លោក អិន វ៉ាន វិបុល បណ្ឌិតច្បាប់ ឯកទេសច្បាបប់សាធារណៈជាចៅក្រមសាលាឧទ្ធរណ៍ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦
- ឯកសារមេរៀននីតិវិធីព្រហ្មទណ្ឌជាលក្ខណៈស្លាយ រៀបរៀងដោយ លោក ចក សម្បត្តិ អនុប្រធាន សមាគមត្រាជូ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

## ៤.គេហទំព័រ

- កម្មវិធីផ្សាព្វផ្សាយច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ភាគ៤,ក្រសួងយុត្តិធម៌ https://youtu.be/p-egR82q1vY,ចូលមើលនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២។

# បញ្ជីរាយនាមឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ឧបសម្ព័ន្ធទី២. ដីកាចាត់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

ឧបសម្ព័ន្ធទី៣. ដីកាសន្និដ្ឋានស្ថាពរ

ឧបសម្ព័ន្ធទី៤. ដីកាបញ្ជូនព័ត៌មាន

ឧបសម្ព័ន្ធទី៥. ដីកាបញ្ជូនរឿងឱ្យពិនិត្យ

ឧបសម្ព័ន្ធទី៦. ដីកាកោះ

ឧបសម្ព័ន្ធទី៧. ដីកាបង្គាប់ឱ្យចូលខ្លួន

ឧបសម្ព័ន្ធទី៨. ដីកាបង្គាប់ឱ្យនាំខ្លួន

ឧបសម្ព័ន្ធទី៩. ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី១០. ដីកាបង្គាប់ឱ្យឃុំខ្លួន

ឧបសម្ព័ន្ធទី១១. ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី១២. ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ឧបសម្ព័ន្ធទី១៣. ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ

ឧបសម្ព័ន្ធទី១៤. ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ

ឧបសម្ព័ន្ធទី១៥. ដីកាបង្គាប់ឱ្យដោះលែង

ឧបសម្ព័ន្ធទី១៦. ដីកាចាត់ឱ្យស៊ើបសួរជំនួស

ឧបសម្ព័ន្ធទី១៧. ដីកាចាត់តាំងអ្នកជំនាញ

ឧបសម្ព័ន្ធទី១៨. ដីកាលើកលែងចោទប្រកាន់

ឧបសម្ព័ន្ធទី១៩. ដីការក្សាការឃុំខ្លួនបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី២០. ដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ

ឧបសម្ព័ន្ធទី២១. ដីកាដំណោះស្រាយ

ឧបសម្ព័ន្ធទី២២. ដីកាបង្គាប់ឱ្យនាំជនជាប់ចោទទៅតុលាការ

ឧបសម្ព័ន្ធទី២៣. ដីកាបង្គាប់ឱ្យស្រាវជ្រាវ និងបំពេញសាវតាជាតិ

ឧបសម្ព័ន្ធទី២៤. ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ឧបសម្ព័ន្ធទី២៥. ដីកាសម្រេចកែប្រែបទល្មើស

ឧបសម្ព័ន្ធទី២៦. ដីកាបង្គាប់ឱ្យចាប់ខ្លួន

ឧបសម្ព័ន្ធទី២៧. ដីកាបញ្ជូនឱ្យឆ្លើយ

ឧបសម្ព័ន្ធទី២៨. ដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន

ឧបសម្ព័ន្ធទី២៩. លិខិតជូនព័ត៌មាន ស្ដីពីការបញ្ចប់ការស៊ើបសួរ

ឧបសម្ព័ន្ធទី៣០. លិខិតជូនដំណឹង ស្ដីពីការបញ្ចប់ការស៊ើបសួរដល់ព្រះរាជអាជ្ញា

ឧបសម្ព័ន្ធទី៣១. ដីកាសម្រេចបដិសេធការស្នើសុំឱ្យបំពេញកិច្ច

ឧបសម្ព័ន្ធទី១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ:៧៣០
ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០២២
លេខ:.......................អ.យ.ណ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង ........................ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញរបាយការណ៍សំយោគលេខ: **០១៩/២២ រ.ប.ក** ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ផែនការងារនគរបាលព្រហ្មទណ្ឌ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ................. ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញមានតម្រុយសន្មតថា៖

-គោត្តនាម និងនាមខ្លួន៖.................................ហៅ **វ៉េង** ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ, មុខរបរ គ្មាន, ទីកន្លែងកំណើតនៅ ខេត្តសៀមរាប , ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅមិនពិតប្រាកដ, នៅលីវ, ឪពុកមិនស្គាល់ឈ្មោះ "រ.ស", ម្ដាយឈ្មោះ..................... "រ.ស", កំរិតវប្បធម៌ថ្នាក់ទី ៣ថ្មី។ (ឃាត់ខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ**[1]៖ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង២៣ និង៤៥នាទី ជនរងគ្រោះឈ្មោះ................ភេទប្រុស អាយុ ៤៤ឆ្នាំ បានសម្រាកនៅចំណុចការដ្ឋានសំណង់ ផ្លូវលំ ក្រុមទី០១ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ដោយទុកទូរស័ព្ទមួយគ្រឿងម៉ាកវីវ៉ូ ពណ៌ខៀវ មានស៊ីមលេខ: ០៩៦៥៧៤២៦៤៦ នៅក្បាលដំណេក ហើយក៏មានជនសង្ស័យឈ្មោះ.............................ហៅ **វ៉េង** ដើរមកដល់ឃើញមានឱកាសស្ងាត់ក៏ផ្លោះរបងចូលក្នុងការដ្ឋានសំណង់ ឃើញទូរស័ព្ទរបស់ជនរងគ្រោះទុកលើក្បាលដំណេក ក៏យកដៃកលួចស្មាខោអាវនៅក្បែរនោះការយកទូរស័ព្ទជនរងគ្រោះបានសម្រេច ហើយត្រូវជនរងគ្រោះភ្ញាក់ដឹងខ្លួនទាន់ស្រែកឆោឡោផ្អើលដល់កម្មករនាំគ្នាជួយចាប់ជនសង្ស័យ ប្រគល់ឲ្យប៉ុស្តិ៍នគរបាល រដ្ឋបាលឫស្សីកែវតែម្តង។

-អំពើប្រព្រឹត្តខាងលើជាបទល្មើស៖ **លួច (ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់ ផ្លូវលំ ក្រុមទី០១ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** មាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ: មាត្រា **៤៤** និងមាត្រា **១២៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ហេតុដូច្នេះ

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☐ ដាក់ឱ្យស្ថិតក្រោមការពិនិត្យ[2] ៖

-ឈ្មោះ...............................ហៅ **វ៉េង** ភេទប្រុស អាយុ ២៩ឆ្នាំ ។ (ឃាត់ខ្លួន)

[1] សេចក្តីសង្ខេបអង្គហេតុ
[2] ឈ្មោះជនត្រូវចោទ

ពីបទ៖ **លួច (ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់ ផ្លូវលំ ក្រុមទី០១ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** មាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[3] ៖.............................................................

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នលើជនសង្ស័យខាងលើ[4] ៖

ថ្ងៃអាទិត្យ ១២កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២២

**តំណាងអយ្យការ**

[3]កាតព្វកិច្ចណាមួយដែលបាននៅក្នុងមាត្រា ២២៣

[4]មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងនៅក្នុងមាត្រា២០៥

ឧបសម្ព័ន្ធទី២. ដីកាចាត់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
លេខ អ.យ.ផ

## ដីកាចាត់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

**យើង**.........................**ព្រះរាជអាជ្ញារង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញមាត្រា ១៣២,២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ **នស/រកម/០៨០៧/០២៤** ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។
- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.................. ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៨ ។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **១៩៣១** អ.យ.ផ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៨ ។
- បានឃើញដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យលេខ **៥១៨** ព្រ.ទ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៨ ។

ក្រោយពីបានពិនិត្យសំណុំរឿង និងភស្តុតាងឃើញថាៈ ពុំទាន់បានស៊ើបសួរសព្វគ្រប់នៅឡើយ ។

ហេតុដូច្នេះ ស្នើសុំលោកចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរបន្ថែម ស្វែងរកសាវតារជាតិ របស់**អញ្ញាតជន** (គ្មានសាវតារជាតិ) ។

បញ្ជូនសំណុំរឿងទៅ លោកចៅក្រមស៊ើបសួរ ដើម្បីចាត់ការតាមនីតិវិធីព្រហ្មទណ្ឌតទៅ ។

ថ្ងៃ ច័ន្ទ ០១ រោច ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៨
**តំណាងអយ្យការ**

ដីកានេះ ព្រះរាជអាជ្ញា ប្រើសម្រាប់ស្នើឱ្យចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរបន្ថែម ឬស្នើសុំឱ្យចេញដីកាដំណោះស្រាយ ។

ឧបសម្ព័ន្ធទី៣. ដីកាសន្និដ្ឋានស្ថាពរ



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ: ១៥៧
ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២២
លេខ:...........................អ.យ.ណ

# ដីកាសន្និដ្ឋានស្ថាពរ

**យើង** ............................ **តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:......... ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: **១៥៥** អ.យ.ណ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ: **១៣២** ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញលិខិតជូនដំណឹង ស្តីពីការបិទការស៊ើបសួរដល់តំណាងអយ្យការលេខ: **២០៣** ព្រ.ទ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខ: **២១៣** ព្រ.ទ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា**[១]:

១-នាមត្រកូល និងនាមខ្លួន៖................................. ហៅ **ស្នា** ភេទ ប្រុស កើតឆ្នាំ២០០៤, ជនជាតិខ្មែរ, ទីកន្លែងកំណើតនៅភូមិស្វាយពក ឃុំអូរាំងឪ ស្រុកអូរាំងឪ ខេត្តកំពង់ចាម, មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួល ភូមិទួលពង្រ សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ, មុខរបរ មិនពិតប្រាកដ, នៅលីវ, ឪពុកឈ្មោះ........................ "រ" ម្តាយឈ្មោះ.............. "រ" ទោសពីមុន ធ្លាប់មានដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ: ៧០៨០ "ឌ" ដ.ព.ស ចុះថ្ងៃទី១២-១២-២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ជាប់ចោទពីបទ៖ លួច ។ (ឃុំខ្លួន)

២-ឈ្មោះ.................................. ភេទប្រុស អាយុប្រហែល ២២ឆ្នាំ ។ (គេចខ្លួន)

-ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចបន្ទប់ជួលលេខ២ ផ្លូវលំ ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

**អំពីអង្គហេតុ**[1]៖ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ មុនវេលាម៉ោង ១១ និង១៥នាទី ជនត្រូវចោទឈ្មោះ.................. ហៅ **ស្នា** និងជនត្រូវចោទឈ្មោះ...................... ភេទប្រុស អាយុប្រហែល ២២ឆ្នាំ បាននាំគ្នាយកដែកលួសសរសៃកែច្នៃចុងស្រួចធ្វើសកម្មភាពចាក់ផ្តិះមេសោដែលចាក់ទ្វារបន្ទប់ជួលលេខ២ ស្ថិតនៅផ្លូវលំ ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ របស់ជនរងគ្រោះឈ្មោះ................. ភេទប្រុស អាយុ ៣៣ឆ្នាំ ចូលរើកកូរកកាយលួចយកទ្រព្យសម្បត្តិនៅក្នុងបន្ទប់ដោយជនត្រូវចោទឈ្មោះ......................ជាអ្នកចាំមើលផ្លូវហើយត្រូវជនរងគ្រោះមកទាន់ក៏ឃាត់ខ្លួនជនត្រូវចោទឈ្មោះ.......................រួមទាំងវត្ថុតាងប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី១ ចំណែកជនត្រូវចោទឈ្មោះ...........................បានរត់គេចខ្លួនបាត់ ។

[១] រៀបរាប់សង្ខេបអង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់
(ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ)

**បានឃើញ ៖**

-ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឈ្មោះ.......................ភេទប្រុស អាយុ ៣៣ឆ្នាំ នៅសមត្ថកិច្ច បានឆ្លើយថា៖ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៧ និង០០នាទី រូបខ្លួន បានចាក់សោបន្ទប់ជួលលេខ២ ផ្លូវលំ ភូមិត្រពាំងឈ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ត្រឹមត្រូវមុននឹងចេញទៅធ្វើការរោងចក្រដូចសព្វដង ។ រហូតដល់ម៉ោង ១១ និង១៥នាទី ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ដដែលនៅពេលខ្លួនចេញពីធ្វើការរោងចក្រ ត្រឡប់មកដល់បន្ទប់ជួលខាងលើ ស្រាប់តែឃើញបន្ទប់ជួលរបស់ខ្លួនបើកទ្វារចំហរ និងឃើញជនត្រូវចោទម្នាក់កំពុងរើកកាយអីវ៉ាន់ និងលួចយកកាបូបដាក់លុយពណ៌ផ្កាឈូកចំនួន០១ នៅពេលឃើញរូបខ្លួនភ្លាមស្រាប់តែជនត្រូវចោទបានរត់គេចខ្លួនពីបន្ទប់ជួលកន្លែងកើតហេតុ ទើបខ្លួនបានដេញតាមពីខាងក្រោយ និងស្រែកឆោឡោថា: "ចោរៗ" ហើយក៏មានអ្នកជិតខាងចេញមកជួយ និងបានឃាត់ជនត្រូវចោទឈ្មោះ......................ភេទប្រុស រួមនឹងវត្ថុតាងចាប់យកដាក់ស្ដែងនាំយកមកប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី១ ដើម្បីសាកសួរ ហើយខ្លួនបានដាក់ពាក្យបណ្ដឹងប្ដឹងចោទប្រកាន់ទៅលើជនត្រូវចោទឈ្មោះ............................ ដើម្បីឲ្យសមត្ថកិច្ចនគរបាល ចាត់តាមនីតិវិធីតែម្ដង ។ (ឯ.១/៣៨)

-ចម្លើយរបស់សាក្សីឈ្មោះ..........................ភេទប្រុស នៅសមត្ថកិច្ចបានឆ្លើយថា៖ នៅថ្ងៃទី១១ ខែមករា ឆ្នាំ វេលាម៉ោង១០ និង១០នាទី រូបខ្លួនគឺជាអ្នករត់ម៉ូតូឌុបកំពុងអង្គុយឈប់ចាំដឹកម៉ូយនៅខាងមុខផ្ទះជួល ភូមិពាំងឈ្លឹង១ សង្កា ចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពេលនោះរូបខ្លួនបានឃើញជនត្រូវចោទចំនួន ០២នាក់ ភេទប្រុស បានដើរចូលទៅធ្វើសកម្មភាពគាស់ទ្វារបន្ទប់ជួលលេខ២ ជាន់ផ្ទាល់ដីចូលលួចសម្ភារៈ ក្រោយមកក៏ឃើញម្ចាស់បន្ទប់ជួលគេមកទាន់ ក៏បានព្យាយាមឃាត់ខ្លួនក្រុមជនត្រូវចោទទាំង០២នាក់ ហើយពេលនោះក៏មានជនត្រូវចោទម្នាក់បានរត់គេចខ្លួនបាត់ រួចម្ចាស់បន្ទប់ជួលបានឃាត់ខ្លួនជនត្រូវចោទម្នាក់ទៀតនាំយកមកប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី១ ដើម្បីធ្វើការសាកសួរ ហើយជនរងគ្រោះ ជាម្ចាស់បន្ទប់ជួល ក៏បានដាក់ពាក្យបណ្ដឹងប្ដឹងចោទប្រកាន់ទៅលើជនត្រូវចោទម្នាក់ឈ្មោះ..........................ដើម្បីឲ្យសមត្ថកិច្ចនគរបាល ចាត់ការតាមនីតិវិធីតែម្ដង ។ (ឯ.១/៣៧)

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ...............................ភេទប្រុស អាយុ១៨ឆ្នាំ នៅសមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរ បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១១ និង១៥នាទី មុនពេលកម្លាំងសមត្ថកិច្ចនគរបាលឃាត់រូបខ្លួន និងបក្ខពួកឈ្មោះ..............................ភេទប្រុស អាយុប្រហែល២២ឆ្នាំ (ទីលំនៅមិនពិតប្រាកដ) បាននាំគ្នាចេញពីកន្លែងលេងហ្គេមតាមអ៊ិនធើណេត នៅភូមិទួលពង្រ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយពួកខ្លួនដាច់លុយចាយក៏បែកគំនិតទៅដើរគាស់បន្ទប់ជួល ដើម្បីលួចយកទ្រព្យសម្បត្តិ រួចហើយពួកខ្លួនក៏បានហៅម៉ូតូកង់បី (តុកតុក) ទៅម្តុំផ្ទះជួល នៅភូមិត្រពាំងឈ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ នៅពេលទៅដល់ចំណុចផ្ទះជួលកន្លែងកើតហេតុខាងលើ ដោយឃើញមានឱកាសស្ងាត់មនុស្សល្អទើបខ្លួន និង.........................នាំគ្នាដើរចូលទៅក្នុងផ្ទះជួលដើម្បីគាស់ទ្វារតាមបន្ទប់ជួលចូលលួចយកទ្រព្យសម្បត្តិ បន្ទាប់មកឈ្មោះ..............................បានយកដែកល្អសសរសៃកែច្នៃចុងស្រួចទៅធ្វើសកម្មភាពចាក់ផ្ដិះមេសោដែលបានចាក់ជាប់នឹងទ្វារបន្ទប់ជួលលេខ២ បានសម្រេចរួច ហើយឈ្មោះ.....................បានឲ្យរូបខ្លួនជាអ្នកចូលទៅធ្វើសកម្មភាពរើកកាយនៅក្នុងបន្ទប់ជួល ដើម្បីលួចយកទ្រព្យសម្បត្តិនៅក្នុងបន្ទប់ជួលខាងលើ ហើយឈ្មោះ..........................ជាអ្នកចាំមើលផ្លូវ បន្ទាប់មកស្រាប់តែម្ចាស់បន្ទប់ជួលគេមកទាន់ ក៏បានឃាត់រូបខ្លួននាំយកមកប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍ នគរបាលរដ្ឋបាលចោមចៅទី១ ដើម្បីសាកសួរតែម្ដង ចំណែកឈ្មោះ..........................បានគេចខ្លួនបាត់ រយៈកាលកន្លងមករូបខ្លួនពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ប៉ុន្តែកាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ រូបខ្លួន និងបក្ខពួកឈ្មោះ..................... ហៅ..........................ភេទប្រុស ធ្លាប់ធ្វើសកម្មភាពលួច (យកសត្វមាន់ចំនួន០១ក្បាល) កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួន បញ្ជូនទៅកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធី ប៉ុន្តែត្រូវបានលោកចៅក្រម

ស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ សម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ចំណែកគ្រឿងញៀន គឺខ្លួនចេះជក់ជាប្រចាំ និងធ្លាប់ជាប់មណ្ឌលបន្សាបគ្រឿងញៀន ។ (ឯ.១/៣៧, ៥/២)

-ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខៈ **៧០៨០** "ឆ" ដ.ព.ស ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.១/៥)

-ពាក្យបណ្ដឹង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ....................... ។ (ឯ.១/៣០)

-របាយការណ៍សំយោគលេខៈ **០០៧/២២** រ.ប.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ ស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ សន្និដ្ឋានថាៈ១.ឈ្មោះ....................... និង២.ឈ្មោះ................. ពិតជាបានប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោស** ពីជនរងគ្រោះឈ្មោះ........................... ប្រាកដមែន ។ (ឯ.១/៣៩, ១/៣៦)

-ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខៈ **២៦០** "ថ" ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.៦/៣)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ **៣៥៧** "ថ"ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.៧/២)

-ដីកាចាត់ឲ្យស៊ើបសួរជំនួសលេខៈ ៤៨ ព្រ.ទ/២២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ (ឯ.៨/១)

-លិខិតលេខៈ **៤៨៥** "ថ" រ.ប/២២ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួររបស់សាលាដំបូងរាជធានីភ្នំពេញ ស្ដីពីការលើកដីកាចាត់ឲ្យស៊ើបសួរជំនួស ។ (ឯ.៨/៣)

-ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងសំណុំរឿង ។

## **យល់ឃើញថា**[2]

-ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឈ្មោះ...................................ភេទប្រុស អាយុ ៣៣ឆ្នាំ, ចម្លើយរបស់ជនត្រូវចោទឈ្មោះ................................ ហៅ **ស្វា** ភេទ ប្រុស កើតឆ្នាំ២០០៤ និងចម្លើយរបស់សាក្សីឈ្មោះ................ ភេទប្រុស និងពាក្យបណ្ដឹង, របាយការណ៍សំយោគរបស់សមត្ថកិច្ច រួមទាំងភស្តុតាងនានាបញ្ជាក់ថាៈ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១១ និង១៥នាទី នៅផ្ទះជួលបន្ទប់លេខ២ ភូមិតាំងប្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានជនត្រូវចោទចំនួន ០២នាក់ៈ ១.ឈ្មោះ........................... ហៅ **ស្វា** ២.ឈ្មោះ.....................ពិតជាបានធ្វើសកម្មភាពយកដែកលួសសរសៃកែច្នៃចុងស្រួចទៅចាក់ផ្ដិះមេសោគាស់ទ្វារបន្ទប់ជួលរបស់ជនរងគ្រោះ លួចយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះឈ្មោះ...................................ប្រាកដមែន ។

-អំពើប្រព្រឹត្តរបស់ជនត្រូវចោទឈ្មោះ................................................ហៅ **ស្វា** ភេទប្រុស កើតឆ្នាំ២០០៤ និងឈ្មោះ........................... ភេទប្រុស អាយុប្រហែល ២២ឆ្នាំ មានចេតនាក្នុងការប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោស** មានចែងតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

-ជនត្រូវចោទឈ្មោះ.........................ហៅ **ស្វា** ភេទប្រុស កើតឆ្នាំ២០០៤ មានសតិស្មារតី គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ នូវអំពើដែលខ្លួនបានប្រព្រឹត្ត ។

[2] សំអាងហេតុ សំអាងច្បាប់

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ.......................................... ហៅ **ស្នា** កើតឆ្នាំ២០០៤ និង ឈ្មោះ............................. ភេទប្រុស អាយុប្រហែល២២ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចបន្ទប់ជួល លេខ២ ផ្លូវលំ ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

-សាវតារជាតិរបស់ជនត្រូវចោទឈ្មោះ............................ភេទប្រុស អាយុប្រហែល២២ឆ្នាំ សមត្ថកិច្ចពុំទាន់បញ្ជូនលទ្ធ ផលស្តីពីស្វែងរកសាវតារជាតិ តាមដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ នៅឡើយ ។

-ហេតុដូចនេះ ដើម្បីពន្លឿននីតិវិធី គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយបញ្ជូនជនត្រូវចោទឈ្មោះ ................................ហៅ **ស្នា** កើតឆ្នាំ២០០៤ ទៅជំនុំជម្រះ និងលើកលែងចោទប្រកាន់លើឈ្មោះ.............................ភេទ ប្រុស អាយុប្រហែល២២ឆ្នាំ គ្មានសាវតារជាតិ តាមបញ្ញត្តិមាត្រា **២៤៧** ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា **២៤៧**, មាត្រា **៣៦៨**, មាត្រា **៣៧២** និងមាត្រា **៣៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**<u>ហេតុដូច្នេះ</u>**

ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច៖

□ បញ្ជូនជនត្រូវចោទ៖

-ឈ្មោះ.......................... ហៅ **ស្នា** ភេទប្រុស កើតឆ្នាំ២០០៤ (ឃុំខ្លួន) ទៅជុំនុំជម្រះ ។

ពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចបន្ទប់ជួលលេខ២ ផ្លូវលំ ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃ ក្រមព្រហ្មទណ្ឌ ។

□ លើកលែងចោទប្រកាន់លើ៖

-ឈ្មោះ............................. ភេទប្រុស អាយុប្រហែល២២ឆ្នាំ (គ្មានសាវតារជាតិ) ។

ពីបទ៖ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចបន្ទប់ជួលលេខ២ ផ្លូវលំ ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃ ក្រមព្រហ្មទណ្ឌ ។

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

**តំណាងអយ្យការ**

ឧបសម្ព័ន្ធទី៤. ដីកាបញ្ជូនព័ត៌មាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខៈ...........
ចុះថ្ងៃទី..........ខែ...........ឆ្នាំ.............
លេខ...................../

**ដីកាបញ្ជូនពត៌មាន**

យើង.......................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ។

បញ្ជាឲ្យបញ្ជូនសំណុំរឿងស៊ើបសួរទាក់ទងនឹងជនត្រូវចោទឈ្មោះ

.................................................................................................................................

.................................................................................................................................

.....................................ពីបទ៖.............................................................................................

..........................................ប្រព្រឹត្តនៅ.......................................................................

